ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ THE MESSENGER

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១១ សម្រាប់ខែ កុម្ភៈ ឆ្នាំ ២០១៩ | តម្លៃលក់ ១០០០រៀល លេខ #១១៧

## កាស៊ីណូ មិនមែនសម្រាប់ ពលរដ្ឋកម្ពុជា

> ទំព័រ ១០-១១



CSC

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០២០/១៨ ព.ម.រ.ល.អ/ ០១-មករា-២០១៨
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# តើមនុស្សវ័យជំទង់ និងយុវវ័យគួរ និយាយអំពីបញ្ហាផ្លូវភេទដែរឬទេ ?

**រហូតមកដល់ពេលបច្ចុប្បន្ននេះ បញ្ហាផ្លូវភេទ គឺជាប្រធានបទមួយដ៏ចាប់អារម្មណ៍ពីគ្រប់មជ្ឈដ្ឋាន។ ពោលគឺសម្រាប់មនុស្សគ្រប់វ័យ លើកលែងតែកុមារ ហើយក៏មានបញ្ហាអវិជ្ជមាន និង សំណួរជាច្រើនកើតឡើង ជុំវិញថា តើមនុស្សវ័យជំទង់ និងយុវវ័យ គួរនិយាយអំពីបញ្ហាផ្លូវភេទនេះដែរឬទេ ? មូលហេតុដែលវាលេចចេញជាសំណួរ និងបញ្ហាជុំវិញសំណួរនេះ គឺដោយសារតែផលប៉ះពាល់សង្គមដ៏អវិជ្ជមាន ទាក់ទងនឹងបញ្ហាផ្លូវភេទនេះ។**

សង្គមកម្ពុជា តាំងពីដើមរៀងមក ហាក់មាននិន្នាការបិទបាំង និងមិនចង់ឲ្យមនុស្សវ័យជំទង់ និងយុវវ័យ និយាយអំពីបញ្ហាផ្លូវភេទនេះនោះទេ ហើយសូម្បីតែមនុស្សពេញវ័យហើយក៏ដោយ ក៏នៅតែមិនឲ្យតម្លៃទៅលើការនិយាយជាសាធារណៈអំពីបញ្ហាផ្លូវភេទនេះដែរ។

រហូតមកដល់ពេលនេះ មានការនិយាយលេងខ្លះនៅក្នុងចំណោមមនុស្សពេញវ័យ ប៉ុន្តែមិនមែនជាការនិយាយជាសាធារណៈនោះទេ។ វាគ្រាន់តែជាការនិយាយលេងសើច ចំអែចំអន់គ្នា នៅក្នុងមជ្ឈដ្ឋានក្រុមបុរស ប៉ុន្តែប្រសិនបើនិយាយអំពីក្រុមមនុស្សវ័យជំទង់ និង យុវវ័យវិញ គឺមានការនិយាយ ប៉ុន្តែជាការនិយាយលាក់បាំង ជាការនិយាយនៅពីក្រោយខ្នងចាស់ៗ ពីក្រោយខ្នងអាណាព្យាបាល។ ការនិយាយអំពីបញ្ហាផ្លូវភេទជាសាធារណៈ នៅតែត្រូវបានសង្គមកម្ពុជាជាទូទៅចាត់ទុកថា វាគឺជាបញ្ហាសីលធម៌។ ក្រុមមនុស្សវ័យជំទង់ និង យុវវ័យដែលនិយាយអំពីបញ្ហាផ្លូវភេទនេះ ត្រូវបានគេចាត់ទុកថា ជាក្រុមមនុស្សបាតសង្គម។ នោះគឺជាការយល់ឃើញមួយបែបដោយសារតែបញ្ហានេះ ទំនៀមទំលាប់ខ្មែរ ដែលយើងអាចមើល និងសិក្សាតាមរយៈសៀវភៅកំណាព្យ ដូចជា ច្បាប់ប្រុស និង ច្បាប់ស្រីជាដើម គឺសុទ្ធសឹងតែមិនគាំទ្រការនិយាយជាចំហរ អំពីបញ្ហាផ្លូវភេទនេះដែរ។

និយាយឲ្យពិតទៅ រហូតមកដល់ពេលនេះ ក៏នៅតែមានគ្រួសារខ្លះ នៅតែព្យាយាមនិយាយបន្លប់បង្វែរការពិតប្រាប់ទៅបុត្រធីតារបស់ពួកគេថា ពួកគេមិនមែនកើតចេញមក តាមប្រដាប់បន្តពូជនោះទេ គឺបែរជាថា កើតមានតាមផ្ចិតទៅវិញ។ ការនិយាយបែបនេះ គឺដើម្បីមិនចង់ឲ្យក្មេងៗ យល់ដឹងការពិតទាក់ទងនឹងភេទនេះតែម្តង។ នេះគឺជាអំណះអំណាងមួយ ហើយនៅមានរឿងជាច្រើនទៀត ដែលអាចបង្ហាញថា បញ្ហាផ្លូវភេទ មិនមែនជារឿងដែលត្រូវនិយាយជាសាធារណៈ។ ប៉ុន្តែ យើងខ្ញុំមិនគាំទ្រនូវគោលគំនិតបែបអភិរក្សនេះទៀតទេ។

គ្រួសារនីមួយៗគួរតែបើកសិទ្ធិឲ្យពួកគេយល់ច្បាស់អំពីបញ្ហាផ្លូវភេទនេះឲ្យច្បាស់លាស់។ សម្រាប់កុមារភាព មិនគួរនិយាយឲ្យពួកគេដឹងមែន ប៉ុន្តែ នៅពេលដែលពួកគេចម្រើនវ័យដល់ជំទង់ និង ចូលទៅដល់យុវវ័យ ត្រូវតែឲ្យពួកគេដឹងអំពីរឿងនេះ។

ការនិយាយអំពីបញ្ហាផ្លូវភេទ គួរតែនិយាយជាសាធារណៈ ដើម្បីឲ្យពួកគេយល់ពីតួនាទី និងភាពចាំបាច់របស់មនុស្សប្រុស និងមនុស្សស្រីឲ្យបានច្បាស់លាស់។ បញ្ហាផ្លូវភេទ និង ចំណង់ផ្លូវភេទ វាគឺជាសភាវគតិរបស់មនុស្ស ប៉ុន្តែត្រូវតែពន្យល់អំពីហេតុ និងផល ដោយផ្អែកលើកត្តាច្បាប់ ទំនៀមទំលាប់ ប្រពៃណី សីលធម៌ ហើយត្រូវយល់អំពីតួនាទីខុសគ្នារវាងមនុស្សប្រុស និងស្រី។ ពួកគេក៏ត្រូវតែយល់អំពីបញ្ហាអវិជ្ជមាន ដែលអាចកើតមានឡើងនូវបញ្ហាដែលពាក់ព័ន្ធនឹងភេទសម្ពន្ធរវាងបុរស និងស្រី។

អាណាព្យាបាល សង្គម គួរតែបើកឱកាសពន្យល់បំពាក់បំប៉នឲ្យគេយល់ច្បាស់លាស់។ វាគឺជារឿងប្រសើរពីព្រោះវាអាចជាការផ្តល់នូវវិធានការការពារដល់ពួកគេ ដើម្បីឲ្យពួកគេចេះការពារខ្លួន ចេះបង្ការនូវបញ្ហាផ្សេងៗដោយខ្លួនពួកគេ ដែលប្រសើរជាង ការព្យាយាមលាក់បាំងពួកគេ។

នៅសម័យនេះ គ្មានអ្វីអាចលាក់បាំងបានទេ អ្វីៗទាំងអស់គឺនៅលើចង្អុលដៃរបស់មនុស្សគ្រប់រូប ដូច្នេះយើងត្រូវតែឲ្យពួកគេដឹងជាមុន ប្រសើរជាជាងពួកគេដឹងដោយខ្លួនឯង។ ប្រសិនបើ ពួកគេខ្វះការប្រុងប្រៀប គឺអាចបណ្តាលឲ្យពួកគេក្លាយខ្លួនទៅជាជនរងគ្រោះ ដោយសាតែរឿងភេទសម្ពន្ធនេះ។ ជារួម យើងខ្ញុំគាំទ្រនូវគោលគំនិតឲ្យមនុស្សវ័យជំទង់ និង យុវវ័យ និយាយគ្នាដោយចំហរអំពី បញ្ហាទាក់ទងនឹងភេទសម្ពន្ធ និងរវាងទំនាក់ទំនងផ្លូវភេទ ព្រមទាំងរឿងរ៉ាវពិតផ្សេងៗ ដែលបណ្តាលមកពីបញ្ហាផ្លូវភេទនេះ៕





# ប្រកួតបង្ហោះខ្លែងអបអរឆ្នាំថ្មី

*គណៈកម្មការនិងអ្នកជាប់ជ័យលាភីក្នុងកម្មវិធីបង្ហោះខ្លែងឯកនៅព្រះសហគមន៍ព្រះនាងម៉ារីញញឹមចំការទៀង។ រូបភាព៖ ស៊ីអេសស៊ី*

**ព្រះសហគមន៍កាតូលិក សន្តីម៉ារីញញឹមចំការទៀង បានរៀបចំកម្មវិធីប្រកួតបង្ហោះខ្លែង ដើម្បីអបអរសាទរបុណ្យព្រះយេស៊ូប្រសូត និងអបអរសាទរឆ្នាំថ្មី២០១៩ ក្នុងអំឡុងពេលទិយរដូវបានចូលមកដល់។ កម្មវិធីនេះ បានធ្វើឡើងកាលពីថ្ងៃទី១ មករា ២០១៩នេះ នៅឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ដោយមានលោកអភិបាល អូលីវីយេ ជ្មឹតអ៊ីស្លែរ មន្ត្រីរាជការចូលរួម និងប្រជាជនក្នុងឃុំគូស មកចូលរួមយ៉ាងច្រើនកុះករ។**

នៅក្នុងកម្មវិធីនេះ លោកអភិបាល អូលីវីយេ មានប្រសាសន៍ថា នៅក្នុងឆ្នាំ២០១៩ នៅពេលយើងចាប់ផ្តើមដោយមានការប្រកួតខ្លែងឯក នាំឲ្យយើងទាំងអស់គ្នានឹកឃើញថា យើងជាគ្រួសារតែមួយ ព្រោះយើងមានប្រជាជនជាច្រើននៅតាមភូមិផ្សេងៗក្នុងខេត្តតាកែវ។

លោក អភិបាល បានឲ្យដឹងទៀតថា៖ «ក្នុងការប្រកួតខ្លែងថ្នាក់ជាតិខេត្តតាកែវ បានជាប់លំដាប់ថ្នាក់លេខ២។ នេះជាមោទនភាពមួយរបស់ខេត្តនេះ។ សង្ឃឹមថាឆ្នាំក្រោយនឹងទទួលបានលេខ១ ហើយសង្ឃឹមទៀតថា មានថ្ងៃណាមួយ រដ្ឋាភិបាលឯកភាពឲ្យយើងប្រកួតលក្ខណៈជាតិនៅក្នុងចំការទៀងយើង»។



*កម្មវិធីប្រកួតបង្ហោះខ្លែងឯកខ្មែរនេះ បានរៀបចំឡើងរយៈពេល៩ឆ្នាំមកហើយ។ រូបភាព៖ ស៊ីអេសស៊ី*

កម្មវិធីប្រកួតបង្ហោះខ្លែងឯកខ្មែរនេះ បានរៀបចំឡើងរយៈពេល៩ឆ្នាំមកហើយ នៅក្នុងព្រះសហគមន៍កាតូលិក សន្តីម៉ារីញញឹមចំការទៀង ដែលបើកឱកាសដល់ប្រជាពលរដ្ឋទូទៅទាំងចាស់ក្មេង អាចធ្វើខ្លែងឯកផ្ទាល់ខ្លួនមកដាក់ប្រកួតបាន។ ក្នុងឆ្នាំនេះ មានខ្លែងចំនួន២០០ ដើម្បីដាក់ប្រកួត ហើយកម្មវិធីបានចាប់ផ្តើមពីម៉ោង៨ព្រឹករហូតដល់ម៉ោង៦ល្ងាច។ មិនត្រឹមតែមានការប្រកួតខ្លែងប៉ុណ្ណោះទេ កម្មវិធីនេះក៏មានការប្រកួតប្រណាំងសេះ និងរទេះគោផងដែរ។

អង្គុយនៅក្បែរទីលាន ប្រកួតបង្ហោះខ្លែង កញ្ញា កប ធារី ជាអ្នកគាំទ្រម្នាក់ឲ្យដឹងថា នេះជាលើកទី១ហើយ ដែលនាងបានមកមើលការប្រកួតនេះ។ នាងមកគាំទ្របងប្រុសរបស់នាងដែលបានចូលរួមប្រកួតខ្លែង។

ធារី និយាយថា៖ «ខ្ញុំមានអារម្មណ៍មួយសប្បាយចិត្ត ពេលខ្ញុំមកលេងនៅនេះ។ ខ្ញុំមកមួយព្រឹក ហើយតែអត់ទៅវិញ។ ខ្ញុំឃើញថាសប្បាយ។ មើលឃើញមានប្រណាំងសេះ មានបង្ហោះខ្លែង មានប្រណាំងគោ។ អីចឹងមានអារម្មណ៍មួយសប្បាយ ហើយមានអារម្មណ៍មួយថា នៅរំលឹកពីវប្បធម៌ខ្មែរពីមុនមក»។



*ការប្រកួតប្រណាំងសេះ។ រូបភាព៖ ស៊ីអេសស៊ី*

អ្នកចូលរួមប្រកួតការបង្ហោះខ្លែង នៅឆ្នាំនេះ មានភាគច្រើនគឺជាយុវជន ដែលបានធ្វើខ្លែងដោយផ្ទាល់ខ្លួនរបស់ពួកគេ ហើយយកមកប្រកួត។ ការប្រកួតខ្លែងឯកនេះ គឺគិតលើរយៈកម្ពស់របស់ខ្លែង ដោយវាស់ជាដឺក្រេរបស់មុំកែង។ ប្រសិនបើខ្លែងណាមួយទទួលបានមុំខ្ពស់ជាងគេ គឺជាអ្នកឈ្នះ។ នៅក្នុងឆ្នាំនេះ អ្នកទទួលជ័យលាភីលេខ១ គឺជាយុវជន ចេន ចន្ថា អាយុ ១៦ឆ្នាំ មកពីភូមិក្រាំងតាចាន់ ដែលទទួលបានពិន្ទុ ៦៧ដឺក្រេ។

ចន្ថា បានឲ្យដឹងថា ខ្លែងរបស់គាត់បានទទួលជ័យលាភីលេខមួយនេះ ចំនួន៣ឆ្នាំត្រួតគ្នា។ ហើយគាត់ក៏មានខ្លែងទទួលជ័យលាភីលេខ៥មួយទៀតដែរក្នុងឆ្នាំនេះ។ យុវជនរូបនេះ បានសំណូមពរដល់យុវជនទាំងអស់ឲ្យជួយគ្នាអភិរក្សវប្បធម៌មួយនេះ។

ចេន ចន្ថា បាននិយាយដូច្នេះថា៖ «ឲ្យកូនខ្មែរទាំងអស់ចូលរួមរក្សានូវកេរដំណែលស្នាដៃរបស់ខ្មែរ ផលិតផលខ្មែរ»។

នៅមុនពេលបញ្ចប់កម្មវិធីប្រកួតនេះ គណៈកម្មការរៀបចំបានផ្តល់រង្វាន់ដល់ម្ចាស់ខ្លែងឯកពីជ័យលាភីទី១ ដល់ ទី៥ ដែលក្នុងនោះ លេខ១ទទួលបាន ២៦ម៉ឺនរៀល លេខ២ទទួលបាន២៤ម៉ឺនរៀល លេខ៣ទទួលបាន ២២ម៉ឺនរៀល លេខ៤ទទួលបាន២០ម៉ឺនរៀល និងលេខ៥ទទួលបាន១៨ម៉ឺនរៀល។ ចំណែកការប្រណាំងសេះ លេខ១ ទទួលបាន២០ម៉ឺនរៀល លេខ២ទទួលបាន១៦ម៉ឺនរៀល និងលេខ៣ទទួលបាន១២ម៉ឺនរៀល។ រីឯការប្រណាំងរទេះគោ លេខ១ទទួលបានចំនួន១០ម៉ឺនរៀល។ មានការលើកទឹកចិត្តដល់ម្ចាស់ខ្លែងមិនជាប់ជ័យលាភីម្នាក់ៗ ចំនួន៣ម៉ឺនរៀល ៕

# ធនាគារជាតិ៖ សេដ្ឋកិច្ចកម្ពុជានៅបន្តមានស្ថេរភាព

**ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសបានអះអាងថា ស្ថានភាពនៃកំណើនសេដ្ឋកិច្ច និង ម៉ាក្រូសេដ្ឋកិច្ចនៅក្នុងប្រទេស នៅតែបន្តមានស្ថិរភាពសម្រាប់ឆ្នាំ២០១៩នេះ។**



*កំណើនសេដ្ឋកិច្ចជាតិ។ រូបភាព៖ ធនាគារជាតិនៃកម្ពុជា*

របាយការណ៍សន្និដ្ឋានដោយសង្ខេបកម្រាស់៦ទំព័ររបស់ធនាគារជាតិនៃកម្ពុជា ក្រោមចំណងជើងថា៖ វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារឆ្នាំ២០១៨ និងទស្សនវិស័យឆ្នាំ២០១៩” បានអះអាងថា នៅឆ្នាំនេះកម្ពុជានឹងបន្តទទួលកំណើនសេដ្ឋកិច្ចប្រហាក់ប្រហែលនឹងឆ្នាំ២០១៨កន្លងទៅ។

ប្រភពដដែលបានអះអាងថា សេដ្ឋកិច្ចកម្ពុជាត្រូវគេរំពឹងថា នឹងបន្តមានកំណើនក្នុងរង្វង់៧ភាគរយ ហើយអត្រាអតិផរណាបន្តស្ថិតក្នុងកម្រិតទាប ២,៦ភាគរយ ជាមួយនឹងស្ថិរភាពនៃអត្រាប្តូរប្រាក់ ៤.០៥០រៀលក្នុងមួយដុល្លារអាមេរិក។ ទុនបម្រុងអន្តរជាតិរំពឹងថានឹងបន្តកើនដល់ ១១,៣ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលទំនិញ និងសេវាបានប្រមាណ ៥ខែ។ ម្យ៉ាងទៀតឥណទានវិស័យធនាគាររំពឹងថា នឹងបន្តកើនឡើងក្នុងល្បឿន១៧,១ភាគរយ និងបរិយាប័ន្នហិរញ្ញវត្ថុនឹងបន្តកើនឡើងជាលំដាប់ ដែលកត្តាទាំងនេះនឹងបន្តរួមចំណែកជំរុញការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្របន្ថែមទៀត។

នេះគឺជាការព្យាករណ៍ដ៏វិជ្ជមាន ទោះបីជាគេដឹងថា កម្ពុជាកំពុងតែប្រឈមមុខនឹងបញ្ហាប្រឈមមួយចំនួនផងដែរ ដែលបណ្តាលមកពីទាំងកត្តាខាងក្រៅ និងខាងក្នុង ដោយរួមមាន តាំងពីការគម្រាមដកយកមកវិញនូវការអនុគ្រោះពន្ធនាំចូលពីសហភាពអឺរ៉ុបតាមគម្រោង “ អ្វីៗគ្រប់យ៉ាងលើកលែង តែអាវុធ” ដែលហៅកាត់ថា EBA និងបញ្ហាប្រឈមដែលបណ្តាលមកពីការបន្តងើបឡើងនៃសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ដែលនាំឲ្យធនាគារកណ្តាលមួយចំនួននៃប្រទេសទាំងនេះ ជាពិសេស សហរដ្ឋអាមេរិក បន្តធ្វើប្រក្រតិកម្ម គោលនយោបាយរូបិយវត្ថុ តាមរយៈការដំឡើងអត្រាការប្រាក់គោល។

ការដំឡើងនេះ បាននឹងកំពុងធ្វើឲ្យមូលធនហូរទៅរកប្រទេសទាំងនេះវិញ ដែលបានធ្វើឲ្យប្រភពទុនលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងតំបន់ថយចុះ និងជាកត្តាធ្វើឲ្យអត្រាការប្រាក់កម្ចីក្នុងតំបន់អាចកើនឡើង។ បញ្ហានេះអាចនឹងបង្កើនថ្លៃដើមនៃកម្ចីពីក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា ដែលពឹងផ្អែកលើប្រភពទុនពីខាងក្រៅ។

> “ កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០១៩នេះ នឹងទទួលបានកំណើនសេដ្ឋកិច្ចនៅក្នុងរង្វង់ប្រមាណជា៧,១ភាគរយ។

នេះគឺជាការព្យាករណ៍របស់ធនាគារកណ្តាលរបស់ប្រទេស ដែលស្ថិតនៅក្រោមឆ័ត្ររបស់រាជរដ្ឋាភិបាល ប៉ុន្តែស្ថាប័នហិរញ្ញវត្ថុធំៗ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោកជាដើម ក៏នៅតែ បន្តមានទំនុកចិត្តនឹងអត្រាកំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងរង្វង់ជាង៧ភាគរយផងដែរ។

ក្រៅពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗទាំងនេះ សូម្បីតែស្ថាប័នស្រាវជ្រាវមួយចំនួននៅក្នុងតំបន់ ក៏បានប្រកាសអំពីស្ថិរភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជាផងដែរ។

ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី ដែលហៅកាត់ថា AMRO នៅដើមឆ្នាំ២០១៩នេះ ក៏បានចេញរបាយការណ៍ព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយស្ថិរភាពផងដែរ។

ស្ថាប័នតំបន់ដែលមានមូលដ្ឋាននៅសិង្ហបុរី មួយនេះ បានប្រកាសថា កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០១៩នេះ នឹងទទួលបានកំណើនសេដ្ឋកិច្ចនៅក្នុងរង្វង់ប្រមាណជា ៧,១ភាគរយ ដោយអត្រាអតិផរណានៅក្នុងរង្វង់២,៦ភាគរយដដែល ដោយសារតែកម្ពុជានៅតែមានស្ថិរភាពនៅក្នុងការទទួលលំហូរវិនិយោគទុនពីខាងក្រៅ។ ប៉ុន្តែ ស្ថាប័ននេះ ក៏នៅតែលើកទឹកចិត្តឲ្យកម្ពុជាលើកកម្ពស់សមត្ថភាពនៃការប្រកួតប្រជែង ពោលគឺកាត់ថ្លៃដើមផលិត កុំពឹងផ្អែកតែនៅលើទីផ្សារដែលមានការអនុគ្រោះពន្ធ ដូចជា ជា សហរដ្ឋអាមេរិក។

ការព្យាករណ៍ដ៏វិជ្ជមានពីស្ថានភាពសេដ្ឋកិច្ចនាឆ្នាំ២០១៩នេះ គឺមិនអាចបានឡើយ បើកាលពីឆ្នាំចាស់ កម្ពុជាមានវិបត្តិនោះ ប៉ុន្តែកាលពីឆ្នាំ២០១៨កន្លងទៅ របាយការណ៍របស់ធនាគារជាតិកម្ពុជាខាងលើ ក៏បាន សន្និដ្ឋានទៀតថា វិស័យធំៗដែលជាសរសរស្តម្ភនៃកំណើន គឺឈរនៅទីតាំងមួយរឹងមាំ។

ប្រភពដដែលបានឲ្យដឹងថា កាលពីឆ្នាំចាស់ វិស័យកាត់ដេរ សំណង់ និងទេសចរណ៍បន្តមានកំណើនកើនក្នុងអត្រាពីរខ្ទង់ ក្នុងបរិយាកាសអំណោយផលនៃកំណើនសេដ្ឋកិច្ចពិភពលោក និងដោយមានការគាំទ្រពីគោលនយោបាយមួយចំនួន ដែលនាំឲ្យ កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៨ ក្នុងអត្រា ៧,៣ភាគរយ ដែលជាកម្រិតខ្ពស់ ធៀបនឹងអត្រាកំណើនក្នុងរយៈពេល៦ឆ្នាំចុងក្រោយនិងខ្ពស់ជាងអត្រាកំណើនមធ្យមនៃប្រទេសកំពុងលូតលាស់ និងប្រទេសក្នុងតំបន់ទៀតផង។

ទាក់ទងទៅនឹងរឿងស្ថិរភាពសេដ្ឋកិច្ចនេះដែរ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅក្នុង អង្គមិទ្ទិញ រំលឹកខួប៤០ឆ្នាំ នៃការដួលរលំរបបប្រល័យពូជសាសន៍ខ្មែរក្រហម ថា នៅពេលនេះ កម្ពុជាទទួលបានចំណាត់ថ្នាក់ជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងលឿនបំផុតលំដាប់ថ្នាក់ទី៦លើពិភពលោក ដោយសម្រេចបានកំណើនជាមធ្យមជាង៧ភាគរយក្នុង១ឆ្នាំ តាមរយៈការរីកចម្រើនក្នុងកម្រិតខ្ពស់ជាប់មិនដាច់នៃវិស័យឧស្សាហកម្ម កម្មន្តសាល សំណង់ កសិកម្ម សេវាកម្ម ទេសចរណ៍ អចលនទ្រព្យ គមនាគមន៍ និងការដឹកជញ្ជូន។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា ជាលទ្ធផលសេដ្ឋកិច្ចជាតិរីកធំធាត់យ៉ាងឆាប់រហ័ស។ ជាក់ស្តែងផលិតផលសរុបក្នុងស្រុកបានកើនពីប្រមាណ៣.៦៤៩លានដុល្លារ នៅឆ្នាំ២០០០ ដល់ប្រមាណ ២៤.៦០៥លានដុល្លារនៅឆ្នាំ២០១៨។ រចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិកំពុងផ្លាស់ប្តូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកជាសំខាន់លើវិស័យឧស្សាហកម្ម និងសេវាកម្មវិញ។ ផ្លូវ ស្ពាន បណ្តាញអគ្គិសនី ទឹកស្អាត ប្រព័ន្ធធារាសាស្រ្ត មន្ទីរពេទ្យ សាលារៀន ត្រូវបានស្ថាបនាច្រើនស្ទើរស្ទះពាសពេញផ្ទៃប្រទេស។ រោងចក្រ សហគ្រាស កសិដ្ឋាន មជ្ឈមណ្ឌលពាណិជ្ជកម្ម ផ្សារទំនើប អគារខ្ពស់ៗ។ល។ ត្រូវបានកសាង និងពង្រីកកាន់តែច្រើន ដែលបានផ្តល់ការងារជូនប្រជាជនរាប់លាននាក់នៅគ្រប់ទិសទី៕




*រូបភាព៖ ធនាគារជាតិនៃកម្ពុជា*



# ក្រៅពីរោងចក្រកាត់ដេរ កម្ពុជាបង្កើតបានរោងចក្រថ្មីបណ្តើរៗហើយ

**វិស័យឧស្សាហកម្មធុនស្រាលជាពិសេសគឺឧស្សាហកម្មកាត់ដេរដែលបានចាប់កំណើតនៅក្នុងប្រទេសកម្ពុជានៅក្នុងរង្វង់ឆ្នាំ ១៩៩៦ នោះ កំពុងវិវដ្តឈានមួយជំហានទៀតទៅរកឧស្សាហកម្មធុនមធ្យម ហើយកម្ពុជាក៏មានរោងចក្រសហគ្រាសឧស្សាហកម្មថ្មីៗជាច្រើនផងដែរនាពេល បច្ចុប្បន្ននេះ ។**

កម្មករ និងកម្មការនីដែលកំពុងតែស្ថិតនៅក្នុងឧស្សាហកម្មប្រភេទថ្មីៗទាំងនេះ ត្រូវបានគេដឹងថា គឺកំពុងតែមានប្រាក់ចំណូលមួយគួរសម ដែលអាចនឹងមានលើសពីកម្មករ និងកម្មការនី នៅតាមរោងចក្រកាត់ដេរនានា ។

លោក វ៉េត សក្តា ដែលជាកម្មករមួយរូបនៅរោងចក្របង្គុំអេឡិចត្រូនិចមួយនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានឲ្យដឹងថា នៅក្នុងនាមជាអតីតជាងអេឡិចត្រូនិចមួយរូប ហើយមានឱកាសទៅបម្រើការនៅរោងចក្រនោះ សព្វថ្ងៃនេះលោក បានទទួលប្រាក់ប្បៀវត្សរ៍ ប្រមាណជាជិត ៦០០ ដុល្លារ ហើយ នៅមានប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀត ។

លោក សក្តា បានអះអាងថា មិនមែនតែលោកទេ ដែលទទួលប្រាក់ខែនៅក្នុងចំនួននេះ គឺភាគច្រើននៃកម្មករ និងកម្មការនី ដែលបានបម្រើការនៅក្នុងរោងចក្រនោះ ។

តាមការរៀបរាប់របស់ លោក សក្តា នៅមុនពេលត្រូវបានគេជ្រើសរើសកម្មករ និងកម្មការនីនៅរោងចក្រនេះ គឺត្រូវដាក់ពាក្យ នៅពេលដែលរោងចក្របានបើកដំបូង ប្រហែលជា ៥ ទៅ ៦ ឆ្នាំមុននេះ ។ ហើយបន្ទាប់ពីបានដាក់ពាក្យ គេសំភាសន៍ជាប់ គឺត្រូវបានរោងចក្របញ្ជូនទៅ រៀននៅប្រទេសថៃ មួយរយៈ ហើយខ្លះមានទៅរហូតដល់ប្រទេសជប៉ុន ហើយមកវិញ បានចូលបម្រើការ ។


*រោងចក្រផលិតគ្រឿងអេឡិចត្រូនិករបស់ក្រុមហ៊ុនផលិតរថយន្ត ហ៊ីយ៉ាន់ដាយ (Hyundai) នៅតំបន់អភិវឌ្ឍន៍ ស្កាយលែន SKYLAND សេរិនអិនជី 7NG ក្នុងឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ រូបថត៖ ហ្វេសប៊ុក Jet man*

លោក សក្តា បានបន្តទៀតថា សម្រាប់អ្នកដែលបានជាប់សំភាសន៍ ហើយមានឱកាសទៅរៀន ធ្វើការនៅជប៉ុន គឺ មកវិញ បានប្រាក់ខែខ្ពស់ៗណាស់ ខ្លះចូលខ្ទង់ពាន់ដុល្លារក៏មាន ប៉ុន្តែលោក គឺ បានត្រឹមតែប្រទេសថៃប៉ុណ្ណោះ ។

លោកបានបញ្ជាក់ថា៖ «កុំអីខ្ញុំបានទៅជប៉ុននឹងគេហើយ តែអត់ចេះម៉ាចំណុចពេលគេសំភាសន៍ ដំបូង។ ស្តាយដែរ! »។


*រោងចក្រផលិតគ្រឿងអេឡិចត្រូនិកក្រុមហ៊ុនហ៊ីយ៉ាន់ដាយ។ រូបថត៖ ហ្វេសប៊ុក Jet man*

កញ្ញា ឡេង ចាន់ណា ជាកម្មការនីរោងចក្រកាត់ដេរមួយកន្លែងនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនេះ ក៏បានចែករំលែកថា កញ្ញាក៏ធ្លាប់ចូលរួមដាក់ពាក្យដើម្បីចូលបម្រើការងារនៅ ក្នុងឧស្សាហកម្មផ្សេងពីកាត់ដេរផងដែរ ប៉ុន្តែមិនជាប់។

កញ្ញាបានរៀបរាប់ថា ខ្ញុំឮគេថា អ្នកដែលបានទៅបម្រើការងារនៅរោងចក្រ ដែលមិនមែន ជារោងចក្រកាត់ដេរ គឺមានប្រាក់ខែច្រើនៗណាស់ ហើយខ្ញុំក៏ធ្លាប់បានទៅដាក់ពាក្យដែរ តែ សំភាសន៍មិនជាប់ ។

កញ្ញា ដែលសិក្សាបានត្រឹមតែថ្នាក់ទី ៦ បានរៀបរាប់ថា នេះប្រហែលជាកញ្ញា បានរៀនសូត្រតិចតួចពេកហើយមើលទៅ ពីព្រោះមិត្តភក្តិកញ្ញាដែលបានជាប់ហើយកំពុងតែបម្រើការ នៅក្នុងរោងចក្រថ្មីៗអស់នោះ ភាគច្រើនតាមដែលដឹង ពួកគេខ្លះរៀនចប់ដល់ទៅចប់ថ្នាក់ទី១២ អីឯណោះ។

កញ្ញាបានអះអាងថា៖ «ចង់ដែរ តែបើយើងរៀនបានតិច ! ចឹងបានចង់ផ្តាំទៅប្អូនៗនៅស្រុកអីថា ទោះបីជាស៊ីអត់ស៊ីឃ្លានយ៉ាងណា ត្រូវខំរៀនឲ្យចប់ថ្នាក់ទី ១២ ។ បើមិនអីចឹងទេ គឺ បានតែធ្វើការបានប្រាក់ខែ ១០០ ទៅ ២០០ ដុល្លារ ហ្នឹង » ។

កញ្ញាជា ចាន់ណា ក៏បានផ្តាំផ្ញើរដល់យុវសិស្សទាំងឡាយត្រូវខំសិក្សារៀនសូត្រ បើមានលទ្ធភាពគឺត្រូវតែរៀនឲ្យចប់ចុងចប់ដើម ចាំចេញមករកការងារធ្វើ។ ចង់បានការងារល្អធ្វើ និងមានប្រាក់ខែច្រើន គឺត្រូវតែខំរៀន។

តាមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាប្រទេសកម្ពុជាមានគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ចេញពី ឧស្សាហកម្មកាត់ដេរ និងកាមន្តសាលឲ្យទៅជាឧស្សាហកម្មនិងផលិតកម្មមួយរឹងមាំ ហើយមកដល់ពេលនេះ ជំហានកំពុងតែបោះទៅរកគោលដៅនោះជា បណ្តើរហើយ ។

យោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថា នាពេលបច្ចុប្បន្ននេះ នៅកម្ពុជាមានរោងចក្រឧស្សាហកម្មទាំងអស់ចំនួន ១.៥២២ រោងចក្រ ដោយមានពលករសរុបទាំងអស់ចំនួន ៩៨២.២០៣ នាក់ មានតម្លៃបរិមាណផលិតផលសរុប ប្រមាណជា ១០.៧៩៨ លានដុល្លារ ។

ប្រភពដដែលបានបន្តថា នៅក្នុងចំណោមរោងចក្រទាំងអស់នោះ គឺមានរោងចក្រកាត់ដេរ កាត់ស្បែកជើង និងកាបូបចំនួនប្រមាណជា ១.០៣១ កន្លែង ជាមួយនឹងកម្មករ និងកម្មការនីសរុបចំនួន ៨៨៧.៨១៩នាក់។ ក្រៅពីនោះ គឺនៅមានរោងចក្រឧស្សាហកម្មកៅស៊ូ និងប្លាស្ទិកចំនួន ១២០កន្លែង រោងចក្រឧស្សាហកម្មអាហារ និងភេសជ្ជៈចំនួនប្រមាណជា ១២០ កន្លែងថែមទៀត។ ក្រៅពីនោះ ក៏នៅមានរោងចក្រធុនមធ្យម ដូចជា រោងចក្រតម្លើងទោចក្រយាន គ្រឿងបន្លាស់យានយន្ត គ្រឿងបង្គុំ អេឡិចត្រូនិច បរិក្ខាអគ្គីសនី និង សំភារៈ សំណង់ផ្សេងៗ ទៀត ។

ប្រភពដដែលបានបន្តទៀតថា ក្រៅពីរោងចក្រឧស្សាហកម្មខាងលើ កម្ពុជានៅមានសហគ្រាសឧស្សាហកម្មធុនតូចនិង សិប្បកម្មប្រមាណជា ១៥៥.៦៤០ កន្លែង ជាមួយនឹងកម្មករនិងកម្មការនីប្រមាណជា ១,១០ លាននាក់បន្ថែមទៀត ៕



# កែវស្រា និងការរង់ចាំ!

**ការជួបជុំ ជជែកសប្បាយ និងផឹកស្រាកំដរ បច្ចុប្បន្ននេះ វាអាចហៅបានថាជាវប្បធម៌ថ្មីមួយចំពោះប្រជាជននៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែអ្វីដែលគួរតែចាប់អារម្មណ៍នោះ គឺការជ្រុលម៉ោងមិនចូលផ្ទះជាដើម ដែលបង្កឲ្យមានបញ្ហាទំនាស់កើតឡើងក្នុងគ្រួសារ។ ប្តីប្រពន្ធមួយចំនួនបានបញ្ចប់ចំណងគ្រួសារក៏ដោយសារបញ្ហានេះដែរ។ សូមស្តាប់សេចក្តីរាយការណ៍ពីរឿន ស្រីម៉ាចដូចតទៅ៖**

បុរសភាគច្រើនគឺតែងតែចូលចិត្តនូវការជួបជុំមិត្តភក្តិ បងប្អូន ជល់កែវស្រានៅក្រៅផ្ទះដើម្បីផ្លាស់ប្តូរបរិយាកាសឲ្យសប្បាយរីករាយ។ បុរសជាស្វាមីខ្លះ អាចជ្រុលម៉ោងរហូតដល់ដាច់យប់ក៏មាន។ ទង្វើទាំងនេះ បានជះឥទ្ធិពលមួយចំនួនចំពោះជីវិតគ្រួសារ ហើយក៏អាចបង្កឲ្យមានអំពើហិង្សាមួយចំនួនផងដែរ។

អ្នកស្រី អេង គីមឡេ រស់នៅទីក្រុងភ្នំពេញបានឲ្យដឹងថា៖ «ខ្ញុំមិនដែលឃាត់ទេរឿងប្តីផឹក តែកុំឲ្យតែជ្រុលហួសហេតុពេក។ យូរៗម្តងមិនអីទេ តែបើរាល់ថ្ងៃពេក គ្មានស្រីណាទ្រាំបានទោះទេ»។

អ្នកស្រី គីមឡេ បានបន្ថែមទៀតថា អ្នកស្រីធ្លាប់ទាស់ពាក្យសម្តីខ្លះៗជាមួយប្តី ព្រោះតែការដើរផឹករបស់ប្តីជាមួយមិត្តភក្តិរហូតដល់ដាច់យប់ និងបិទទូរសព្ទ។ ពេលត្រឡប់មកវិញ ការសួរនាំបន្តិចបន្តួចក៏កើតជាទំនាស់ពាក្យសំដី។ អ្នកស្រី គីមឡេ៖ «សួរនាំតិចតួចតាំងខឹងថាយើងនិយាយច្រើន តែសួរថាប្តីដើរដាច់យប់ចោលផ្ទះស្រីណាទៅនៅស្ងៀមហើយស្ងប់ចិត្តទៅ»។

ស្ត្រីកូនពីររូបនេះបន្ថែមទៀតថា៖ «ពេលប្តីដើរបាត់ៗចឹងគឺគិតបារម្ភខ្លាចគាត់មានគ្រោះថ្នាក់ ឬមានបញ្ហាអ្វី។ ណាមួយទៀត គេងមិនលក់ទេ ព្រោះនៅផ្ទះជាមួយកូនៗខ្លាចមានបញ្ហាអ្វីកើតឡើង ដូចជា កូនឈឺបន្ទាន់ ឬចោរចូលផ្ទះ ពេលខ្លះគឺសឹងទល់ភ្លឺដេកមិនលក់ទេចាំបើកទ្វារឲ្យប្តីនេះឯង»។

ចំណែកអ្នកស្រី សៅ លក្ខណា ជាអ្នកខេត្តប៉ៃលិនបានឲ្យដឹងផងដែរថា៖ «គិតថាខ្ញុំមានសំណាងទៅចុះដែលប៉ះប្តីមិនចេះដើរផឹកស៊ីស្រីញីខាងក្រៅដូចប្រុសៗមួយចំនួន តែបើប៉ះប្តីដើរផឹកដាច់យប់អីចឹងវិញ មិនដឹងជាដេកពិបាកចិត្តម៉េចទេខ្ញុំ»។

លក្ខណា បន្តថា ស្វាមីនាងក៏ចេះផឹកគ្រឿងស្រវឹងដែរ តែគាត់គោរពពេលវេលាចូលផ្ទះ និងប្រាប់ដំណឹងដើម្បីកុំឲ្យអ្នកនៅផ្ទះបារម្ភ និងចាំមើលផ្លូវ។ លក្ខណា៖ «មិនមែនថាប្តីមិនចេះផឹកអីនោះទេ តែគ្រាន់តែគាត់ដឹងម៉ោងហើយចេះខ្លាចចិត្តយើងជាប្រពន្ធ។ បើទៅផឹកគឺយ៉ាងយូរម៉ោង១០យប់អីអស់ហើយ»។

អ្នកស្រីរូបនេះបន្ថែមទៀតថា៖ «ខ្ញុំសប្បាយចិត្ត និងមានភាពកក់ក្តៅក្នុងចិត្ត ព្រោះមានប្តីចេះយល់ចិត្ត។ ណាមួយយើងទាំងពីរនាក់តែងតែផ្តល់សេរីភាពឲ្យគ្នាទៅវិញទៅមកតាមតម្រូវការ ដូចជាការជួបជុំមិត្តខាងក្រៅនេះ តែធ្វើយ៉ាងណាកុំឲ្យជ្រុលហួស ធ្វើឲ្យប៉ះពាល់អារម្មណ៍ដល់គ្នា និងគ្នា»។

រីឯអ្នកស្រី កែវ នេត្រាជាអ្នកភ្នំពេញបានឲ្យដឹងដែរថា រឿងដើរចោលផ្ទះសម្បែងហើយមកវិញស្រវឹងជោគជាំនេះ អ្នកស្រី ជួបជាច្រើនដងណាស់ ហើយក៏ឈឺចិត្តមិនតិចដងដែរ។ អ្នកស្រីនេត្រា បានឲ្យដឹងបន្ថែមថា ប្តីរបស់អ្នកស្រីតែងតែចូលចិត្តទៅជួបជុំផឹកស៊ីជាមួយមិត្តភក្តិក្រោយបញ្ចប់ការងារនៅកន្លែងធ្វើការ ហើយថែមទាំងជួនកាលមិនចូលផ្ទះទៀតផង។ ទង្វើរបែបនេះច្រើនដងពេកធ្វើឲ្យអ្នកស្រី គិតថាប្តីរបស់ខ្លួនកំពុងមាននារីកំណាន់។

អ្នកស្រី កែវ នេត្រា៖ «ប្រហែលប្តីខ្ញុំមានរឿងអី ឬ ក៏មានស្រីនៅក្រៅបានជាមិនចង់មកផ្ទះវិញ ហើយលុយកាក់ក៏មិនសូវជាសល់ដែរ ព្រោះយកទៅចាយវាយខាងក្រៅអស់ៗ ពេលខ្លះសួរនាំច្រើនកើតជារឿងឈ្លោះគ្នាក៏មាន»។

អ្នកស្រី នេត្រា បន្តថា៖ «ខ្ញុំពិបាកចិត្តព្រោះឲ្យតែពេលគាត់ទៅផឹកនៅក្រៅគឺមិនដែលមកវិញលឿននោះទេ ហើយហៅក្រុបើកទ្វារឲ្យក៏ខឹងដែរទង្វើរនេះគ្មានស្រីណាចង់ជួបនោះទេបើយកប្រពន្ធ ឲ្យនាងពិបាកចិត្តហើយស្រលាញ់កែវស្រាជាងប្រពន្ធនោះ កុំយកប្រពន្ធអី»។

លោក ឧត្តម ជាប៉ូលីសចរាចរណ៍បាននិយាយថា លោកក៏ធ្លាប់ធ្វើទង្វើរដែលបុរសមួយចំនួនបានធ្វើដែររហូតដល់មានទំនាស់ស្ទើរតែបែកបាក់គ្រួសារទៀតផង។ លោក ឧត្តម៖ «ខ្ញុំក៏ធ្លាប់ធ្វើឲ្យប្រពន្ធពិបាកចិត្តដោយសារតែការជួបជុំមិត្តភក្តិញឹកពេកហើយយប់ជ្រៅ រហូតដល់ប្រពន្ធសុំលែងលះផង។ ដំបូងៗគិតថាគ្រាន់តែរឿងបែបហ្នឹងសោះ មិនគួរប្រពន្ធខឹងខ្លាំង ហើយសុំលែងលះ»។

លោក ហេង ឧត្តម បានឲ្យដឹងថា៖ «ទាំងខ្ញុំទាំងគេ អ្នកណាក៏ចូលចិត្តសប្បាយ ហើយការសប្បាយក្នុងការជួបជុំនេះ គ្មានអីក្រៅពីការជួបជុំមិត្តនៅខាងក្រៅ ដើម្បីជប់លៀងផឹកជជែកគ្នាពីនេះពីនោះអីហ្នឹង»។

លោកឧតម្ត បន្ថែមថា ក្រោយពីមានអន្តរាគមន៍ពីចាស់ទុំ និងការត្រិះរិះពិចារណារបស់ខ្លួន លោកទទួលស្គាល់ថា ខ្លួនបានធ្វើហួសហេតុ។ លោកឧតម្ត៖ «ប្រពន្ធហាមប្រាមព្រោះតែនាងស្រលាញ់ហើយបារម្ភពីយើង ចង់បានភាពកក់ក្តៅពីប្តី ហើយណាមួយតួនាទីជាប្តីក៏មិនត្រូវដើរចោលប្រពន្ធកូនដាច់យប់បែបនេះដែរ»។

លោកបន្តថា៖ «ហេតុនេះ ប្តីទាំងអស់គួរគិតឡើងវិញ ពេលយើងនៅលើវមានម្តាយនៅរង់ចាំផ្លូវទោះយប់ជ្រៅយ៉ាងណាក៏ដោយ តែពេលយើងមានគ្រួសា ឬមានប្រពន្ធជាអ្នកចាំផ្លូវទាំងក្តីបារម្ភ។ ហេតុនេះកុំឲ្យការសប្បាយរបស់យើង ក្លាយជាការពិបាកចិត្តរបស់មនុស្សដែលយើងស្រលាញ់។ កុំឲ្យសប្បាយក្លាយជាទុក្ខ»។



# សម្លរឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារភរិយា

**នៅក្នុងសង្គមខ្មែរ កិច្ចការងារក្នុងផ្ទះ ជាទូទៅ គឺជាតួនាទីរបស់ស្ត្រីជាភរិយា។ ស្ត្រីមេផ្ទះមួយចំនួនបានអះអាងថា កិច្ចការងារផ្ទះ គឺជាចំណុចមួយដើម្បីចងចិត្តស្វាមីរបស់ខ្លួន និងដើម្បីមានសុភមង្គលក្នុងគ្រួសារ។ ផ្ទះស្អាត សុខភាពល្អ និងគ្រួសាររុងរឿង ទាំងនេះគឺបានមកពីការរៀបចំទុកដាក់របស់ស្ត្រីជាមេផ្ទះ។ ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ននេះ សង្គមបានប្រែប្រួលខ្លះៗទៅហើយ។ ស្ត្រីមួយចំនួនដែលជាភរិយា ក៏ត្រូវតែជួយរកកម្រៃមួយចំនួនដើម្បីផ្គត់ផ្គង់គ្រួសារផងដែរ។ ស្ត្រីភាគច្រើនបានយល់ឃើញថា កិច្ចការងារផ្ទះក៏ត្រូវការមានអ្នកជួយដែរ។ មានស្វាមីមួយចំនួនក៏បានឯកភាពរឿងនេះដែរ គឺការធ្វើយ៉ាងនេះនឹងធ្វើឲ្យគ្រួសារទទួលសុភមង្គល។**

*ដោយ៖ រឿន ស្រីម៉ាច*



*គ្រួសារមានសុភមង្គលដោយសារការយល់ចិត្តគ្នា និងចេះសម្របសម្រួលគ្នាដោយផ្តល់សិទ្ធិនិងសេរីដល់ដៃគូ។ រូបភាព៖ ស៊ីអេសស៊ី*

សុភមង្គលក្នុងគ្រួសារ គឺជារឿងចាំបាច់បំផុតដែលស្វាមី និងភរិយាគ្រប់រូបប្រាថ្នាចង់បាន ដោយសារការយោគយល់អធ្យាស្រ័យដល់គ្នា ការយកចិត្តទុកដាក់គ្នា និងការផ្គាប់ចិត្តគ្នាជាដើម។ ក្នុងសង្គមខ្មែរ ភរិយាភាគច្រើនមានតួនាទីសំខាន់ក្នុងការថែរក្សា និងបង្កើននូវរសជាតិនៃសុភមង្គលក្នុងគ្រួសារ តាមរយៈការរៀបចំផ្ទះសម្បែង និងចាត់ចែងម្ហូបអាហារជូនស្វាមីខ្លួន ក្រោយពេលដែលគាត់មកពីធ្វើការអស់កម្លាំង និងត្រូវការម្ហូបឆ្ងាញ់ៗដើម្បីបំប៉នកម្លាំង។

ទោះបីជាយ៉ាងណា ស្ត្រីជាច្រើននៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន គឺមានការងារដែលអាចរកចំណូលបានដែរ។ តួយ៉ាងដូចអ្នកស្រី ចាន់ រតនា វ័យ ៤៥ឆ្នាំប្រកបរបរជាអ្នកលក់លៀសហាល បានឲ្យដឹងថា ដោយសារតែជីវភាពក្រីក្រ អ្នកស្រីត្រូវតែចេញទៅរកស៊ីលក់ដូរបន្ថែមទៀត ដោយក្រោកពីព្រលឹម និងចូលផ្ទះវិញនាពេលព្រលប់។ អ្នកស្រីបញ្ជាក់ថា គាត់គ្មានពេលវេលាសម្រាប់ធ្វើកាងារផ្ទះនោះឡើយ។

អ្នកស្រីរតនា៖ «បើក្រឡេកមកមើលការរស់នៅរបស់ខ្ញុំវិញ គឺកូនម្តងឈឺម្តងជា បាយទឹកមិនដឹងណាណើទេ ហើយប្តីដោយប្តី កូនដោយកូន ផ្ទះវិញគឺរប៉ាត់រប៉ាយ ព្រោះថា ក្មេងចូលចិត្តអ៊ើុះហើយគ្មានអ្នករៀបចំទៀត គឺសឹងតែគ្មានកន្លែងអង្គុយតែម្តង»។

អ្នកស្រីបានបន្តទៀតថា នៅពេលត្រឡប់មកដល់ផ្ទះវិញ គាត់ត្រូវចំអិនម្ហូប ហើយបើមានពេលគាត់ក៏ឆ្លៀតរៀបចំផ្ទះឲ្យមានរបៀបបន្តិចទៅ ព្រោះពេលខ្លះគាត់ក៏អស់កម្លាំងខ្លាំងណាស់ដែរ។

អ្នកស្រីរតនាបន្ថែមថា៖«ធម្មតាចិត្តខ្ញុំជាស្រីគឺតែងតែចង់បំពេញនាទីជាម្តាយ និងប្រពន្ធឲ្យល្អ ហើយមើលការខុសត្រូវក្នុងផ្ទះឲ្យបានល្អដែរ តែដោយថា បើនៅតែផ្ទះគឺគ្មានលុយដើម្បីផ្គត់ផ្គង់ជីវភាពនោះទេ ហេតុនេះគឺត្រូវតែធ្វើ។ ហើយជួនកាលឈ្លោះប្រកែកគ្នាដោយសារតែរឿងផ្ទះសម្បែង បាយទឹកនេះផងក៏មាន»។

អ្នកស្រី ថន ដានី ជាមេផ្ទះ រស់នៅក្នុងទីក្រុងភ្នំពេញបាននិយាយថា ពាក្យស្លោកខ្មែរបានពោលថា សម្លរឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារភរិយា គឺជាពាក្យមួយសម្រាប់ដាស់តឿនដល់ស្ត្រីទាំងអស់កុំឲ្យភ្លេចរឿងចង្ក្រានជើងឆ្នាំង។ អ្នកស្រីថា តួយ៉ាងដូចជាអ្នកស្រីផ្ទាល់ គឺតែងតែមមារញឹកជាមួយនឹងរឿងបាយទឹកប្តីកូនៗ និងផ្ទះសម្បែងរាល់ថ្ងៃ ស្ទើរតែរកពេលសម្រាកមិនបានផង។ អ្នកស្រីបន្តថា កិច្ចការទាំងនេះ គឺដើម្បីសម្រួលដល់ការរស់នៅក្នុងក្រុមគ្រួសារឲ្យមានសភាពល្អប្រសើរ និងឲ្យសមាជិកក្នុងផ្ទះមានភាពសប្បាយរីករាយក្នុងការរស់នៅជាមួយគ្នា។

អ្នកស្រីដានី បានបន្ថែមទៀតថា៖ «ខ្ញុំមិនដែលយកពេលទំនេរទៅលេងល្បែង ឬអង្គុយប្រជុំគ្នានិយាយដើមអ្នកនេះអ្នកនោះ ហើយទុកឲ្យផ្ទះរបស់ខ្លួនមានសភាពស្រកេកស្រកាក គ្មានសណ្តាប់ធ្នាប់នោះទេ។ ផ្ទុយទៅវិញ គឺតែងតែយកពេលវេលាទៅធ្វើការងារផ្សេងដែលមានប្រយោជន៍»។

> **យើងជាសមាជិកក្នុងផ្ទះក៏ត្រូវតែចូលរួមជួយគ្នាបន្តិចម្នាក់ៗ ដើម្បីជួយសម្រួលដល់ភរិយាខ្លះ ហើយគ្រួសារកាន់តែមានភាពស្និទ្ធស្នាលនឹងគ្នា។**

អ្នកស្រីរូបនេះបន្ថែមថា៖ «ជាបទពិសោធន៍ខ្ញុំ គឺគ្រួសារខ្ញុំ មិនដែលមានបញ្ហាអ្វីឡើយ គឺរស់នៅជាមួយគ្នាយ៉ាងសប្បាយរីករាយ។ បើទោះបីជាគ្រួសារក្រីក្រក្តី តែប្តីខ្ញុំនៅតែស្រលាញ់ខ្ញុំ ហើយមិនដែលដើរចោលផ្ទះទៅបាយក្រៅឡើយ ព្រោះខ្ញុំតែងតែរៀបចំទុកដាក់ឲ្យគាត់រាល់ថ្ងៃ»។

ងាកមកស្តាប់អ្នកស្រី សឹម ស្រអែម ជាមេផ្ទះ វ័យ៣៧ឆ្នាំ ជាអ្នកខេត្តកំពង់ធំបានឲ្យដឹងថា៖ «សម្រាប់ខ្ញុំវិញ គឺបើទោះបីជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយក៏មិនដែលភ្លេចខ្លួនថាត្រូវធ្វើអ្វីសម្រាប់គ្រួសារដែរ ដូចជាមុខនាទីជាម្តាយ និងជាប្រពន្ធ។ ហើយប្តីខ្ញុំតែងតែសប្បាយចិត្តនៅពេលដែលត្រឡប់មកផ្ទះវិញ គឺមានម្ហូបញ៉ាំឆ្ងាញ់ ខណៈពេលដែលទៅធ្វើការគឺមានសម្លៀកបំពាក់ស្រាប់ៗ។ រីឯក្នុងផ្ទះវិញក៏មានរបៀបរៀបរយល្អ។ ហេតុនេះ គឺយើងមិនដែលមានបញ្ហាជាមួយគ្នាក្នុងការរស់នៅឡើយ»។

អ្នកស្រី ស្រអែម ក៏បានបន្ថែមឲ្យដឹងទៀតថា បីទាៈជាបុរពនុធមានមុខនាទីជាអុនកផុរីកិចុចការផ្ទះមែនពិត តែក្នុងនោះស្វាមី ក៏ត្រូវជួយជំនួសដៃជើងខ្លះដែរ ទើបគ្រួសារកាន់តែមានសេចក្តីសុខ។

មជ្ឈដ្ឋានទូទៅរិះគន់ចំៗទៅលើស្ត្រីដែលនៅតែផ្ទះ ឬមានមុខងារជាមេផ្ទះ ដោយគ្មានចំណូលមិនចេះរៀបចំផ្ទះសម្បែង និងខ្ជះខ្ជាយប្រាក់កាក់ថាជាស្ត្រីកញ្ជើធ្លុះ និងធ្វើឲ្យសុភមង្គលក្នុងគ្រួសារឈានទៅរកភាពរកាំរកូស និងការបែកបាក់គ្នាជាអាសាបង់ទៀតផង។ ប៉ុន្តែទន្ទឹមនឹងនេះ បច្ចុប្បន្ននេះ គ្រួសារភាគច្រើននៅក្នុងប្រទេសកម្ពុជា មិនថាប្តី ឬប្រពន្ធទេ គឺតែងតែជួយគ្នាក្នុងការងារផ្ទះ ព្រោះថាពួកគាត់ទាំងពីរនាក់ ជាអ្នករកចំណូលដើម្បីផ្គត់ផ្គង់គ្រួសារទាំងអស់គ្នា។

លោក អាំ វ៉ាលីនដា វ័យ៣៦ឆ្នាំបម្រើការក្នុងស្ថាប័នមួយកន្លែងក្នុងទីក្រុងភ្នំពេញ បានបញ្ចេញទស្សនៈថា៖ «ខ្ញុំទទួលស្គាល់ថា កាងារផ្ទះគឺមិនមានភាពងាយស្រួលនោះទេ បើទោះបីជា កាងារនោះមិនសូវធំដុំក៏ដោយ លុះណាតែមានការតាំងចិត្តទើបធ្វើវាបានល្អ»។

លោកថា រាល់ថ្ងៃលោក និងភរិយាគឺតែងតែជួយគ្នាទៅវិញទៅមកក្នុងការបំពេញកិច្ចកាងារផ្ទះសម្បែង ព្រោះម្នាក់ៗសុទ្ធតែចេញទៅបំពេញកាងារខាងក្រៅរៀងៗខ្លួន។ ហេតុនេះ ពេលមកដល់ផ្ទះវិញ លោកត្រូវជួយប្រពន្ធ ដូចជាមើលកូន ឬធ្វើម្ហូប ពេលខ្លះក៏សំអាតផ្ទះផង។

លោកបន្តទៀតថា៖ «តែទោះជាយ៉ាងនេះក្តី ក៏កិច្ចការក្នុងផ្ទះ ប្រពន្ធជាអ្នករ៉ាប់រងច្រើនជាងគ្រាន់តែខ្ញុំដែលជាប្តីចូលរួមជួយសម្រួលខ្លះៗ»។

លោក វ៉ាលីនដា បន្ថែមទៀតថា៖ «ខ្ញុំសូមឲ្យបុរសកុំដាក់បន្ទុកលើស្ត្រីតែម្នាក់ក្នុងការងារផ្ទះ បើទោះបីជាគាត់ជាស្រីត្រូវមាននាទីធ្វើក៏ពិតមែន តែយើងដែលជាសមាជិកក្នុងផ្ទះក៏ត្រូវតែចូលរួមជួយគ្នាបន្តិចម្នាក់ៗ ដើម្បីជួយសម្រួលដល់ភរិយាខ្លះ ហើយគ្រួសារកាន់តែមានភាពស្និទ្ធស្នាលគ្នាផងដែរ»៕

# ការលួចបរបាញ់សត្វល្មើសច្បាប់ ជាហានិភ័យលើវិស័យទេសចរនៅអាហ្វ្រិក

**នៅក្នុងទ្វីបអាហ្វ្រិក ការប្រយុទ្ធប្រឆាំងនឹងការបរបាញ់សត្វល្មើសច្បាប់ គឺនៅចំណុចស្នូលនៃការព្រួយបារម្ភរបស់អ្នកធ្វើការក្នុងវិស័យទេសចរណ៍។ ប៉ុន្តែរាល់សកម្មភាពបរបាញ់សត្វល្មើសច្បាប់ មានជាអាទិ៍ ការបរបាញ់សត្វរមាស និងដំរីនៅតែមានចំនួនច្រើន។**


សាកសពសត្វដំរី ក្រោយការសម្លាប់យកភ្លុកពីការបរបាញ់នៅអាហ្វ្រិក។ រូបភាព៖ National Geographic

វាមានការលំបាកនៅក្នុងការការពារពូជសត្វ ដែលត្រូវបានផ្តោតការយកចិត្តទុកដាក់ និងថែរក្សានៅអាហ្វ្រិក ដូចជា រមាស ឬដំរី។ រឿងនេះក៏បានធ្វើឲ្យអ្នកមានអាជីពខាងវិស័យទេសចរណ៍មានការព្រួយបារម្ភ។ ពួកគេបានដាក់ការសង្ស័យថា រឿងនេះនឹងរាំងខ្ទប់លំហូរអ្នកទេសចរណ៍បរទេសមកលេងទ្វីបអាហ្វ្រិក នេះ ដែលធ្វើឲ្យបាត់ចំណូលយ៉ាងច្រើន។

លោក ណាឡឺឌី ខាបូ ប្រធានសមាគមទេសចរណ៍អាហ្វ្រិក នៅក្នុងឱកាសកិច្ចប្រជុំកំពូលវិស័យទេសចរណ៍នៅអាហ្វ្រិកខាងត្បូង បាននិយាយដោយសង្ខេបថា៖ «វាជាការពិតទង្វើនេះជះឥទ្ធិពលជាអវិជ្ជមានមកលើវិស័យទេសចរណ៍»។

លោក ណាឡឺឌី ខាបូ បន្ថែមថា៖ «មិនថាជាការស្លាប់របស់មនុស្ស ឬសត្វ ដោយសារហេតុផលអ្វី គឺស្លាប់ដូចគ្នា តែនឹងផ្តល់ផលវិបាកដ៏ធ្ងន់ធ្ងរមកលើសកម្មភាពរបស់យើងខាងវិស័យទេសចរណ៍»។

ការស្លាប់របស់សត្វរមាស ១១ក្បាល នៅប្រទេសកេនយ៉ា កាលពីពេលថ្មីៗ នេះនៅតែស្ថិតនៅក្នុងការចងចាំនៅឡើយ។ នាប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ព្រឹត្តិការណ៍ជាច្រើនបានធ្វើឲ្យស្រអាប់រូបភាពតំបន់ការពារសត្វព្រៃនៃទ្វីបអាហ្វ្រិក ដែលជាតំបន់ទាក់ទាញមួយដ៏សំខាន់ក្នុងចំណោមតំបន់ទាក់ទាញទេសចរណ៍ជាច្រើន។ ជាដំបូង គឺការបរាជ័យក្នុងការដឹកជញ្ជូនដែលត្រូវបានរៀបចំមិនបានល្អនូវរមាសចំនួន១១ក្បាលនៃឧទ្យានកេនយ៉ា ទៅទីកន្លែងដទៃទៀត ដែលបណ្តាលឲ្យសត្វរមាសងាប់ដោយសារការខ្វះជាតិទឹក។

លោក ណាជីប បាឡាឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍នៃប្រទេសកេនយ៉ា បានទទួលស្គាល់ថា៖ «នេះគឺជារឿងគួរឲ្យសោកស្តាយណាស់...។ វាច្បាស់ណាស់ថា កិច្ចការនេះអនុវត្តមិនបានល្អដោយមន្ត្រីរបស់ខ្ញុំ ហើយយើងបានប្រកាន់យកវិធានការផ្សេងៗ ដើម្បីជួសជុលរឿងនេះ»។

ជាមួយគ្នានោះដែរ នៅប្រទេសបូស្វាណា ដែលជាជម្រកនៃសត្វដំរីច្រើនបំផុតនៅទ្វីបអាហ្វ្រិក។ ប្រទេសនេះមានកម្លាំងប្រដាប់អាវុធដ៏ខ្លាំងក្លារបស់ខ្លួន ក្នុងការបង្ក្រាបបទល្មើស ដែលបានប្រែក្លាយជាប្រទេសគំរូនៅក្នុងការប្រយុទ្ធប្រឆាំងនឹងការបរបាញ់ខុសច្បាប់។ ប៉ុន្តែនៅដើមខែកញ្ញា ឆ្នាំ២០១៨ អង្គការមួយបានបរិហារអំពីការងាប់របស់ដំរី និងរមាសរាប់រយក្បាល ដែលជាការសម្លាប់រង្គាលមួយមិនធ្លាប់មាន ដែលការស្លាប់នេះ ទាក់ទងនឹងការសម្រេចចិត្តរបស់អាជ្ញាធរក្នុងការដកហូតអាវុធពីអាវុធហត្ថរបស់ខ្លួន។

ឥឡូវមានកិច្ចប្រឹងប្រែងថែរក្សាដោយកម្លាំងដែលត្រូវចល័តរហូត។ ឧក្រិដ្ឋកម្មបរិស្ថានមានតម្លៃច្រើនជាង៧០ពាន់លានដុល្លារ ជារៀងរាល់ឆ្នាំសម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ ទ្វីបអាហ្វ្រិកគឺជាផ្ទាំងស៊ីបសម្រាប់អ្នកបរបាញ់ខុសច្បាប់ ដែលប្រមូលយកភ្លុកដំរី និងខ្នាយរមាស ដើម្បីគ្រាន់តែធ្វើជាវត្ថុកំសាន្តដែលមានតម្លៃខ្ពស់ និងសម្រាប់តម្រូវការវេជ្ជសាស្ត្របុរាណរបស់ទ្វីបអាស៊ី។ ប៉ុន្តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសដែលទទួលយកអ្នកទេសចរណ៍មកមើលសត្វព្រៃ បានពង្រឹងយ៉ាងខ្លាំងក្លានូវមធ្យោបាយរបស់ពួកគេដើម្បីប្រយុទ្ធប្រឆាំងនឹងជំនួញខុសច្បាប់ខាងភ្លុកដំរី។

ការខិតខំប្រឹងប្រែងគឺត្រូវការកងកម្លាំងដែលតម្រូវឲ្យចល័តជាប្រចាំ។ លោក ណាឡឺឌី ខាបូ ពន្យល់ថា៖ «វាមានសារៈសំខាន់ដែលថារដ្ឋាភិបាល និងអ្នកមានអាជីពខាងទេសចរណ៍ចូលរួមគ្នាប្រកាន់យកវិធានការខ្លាំងក្លា និងដាក់ទោសឲ្យបានធ្ងន់ធ្ងរសម្រាប់អ្នកជួញដូរសត្វព្រៃខុសច្បាប់»។

យោងតាមអ្នកនិពន្ធរឿងខ្លីនៃការធ្វើដំណើរទេសចរណ៍នៅទ្វីបអាហ្វ្រិក កញ្ញា អានីតា មេនឌីរ៉ាតតា បានឲ្យដឹងថា ការប្រយុទ្ធនឹងអ្នកជួញដូរសត្វព្រៃខុសច្បាប់ និងអ្នកបរបាញ់សត្វព្រៃខុសច្បាប់ ក៏ជាសំណើររបស់អ្នកទេសចរផងដែរ។

កញ្ញា អានីតា មេនឌីរ៉ាតតា បញ្ជាក់ថា៖ «អ្នកទេសចរណ៍បានប្រាប់យើងថា វាមិនល្អទាល់តែសោះ ដែលសត្វព្រៃនៅតែងាប់។ ការប្រយុទ្ធប្រឆាំងនឹងការបរបាញ់ខុសច្បាប់ គឺនៅចំកណ្តាលនៃក្តីព្រួយបារម្ភរបស់យើង។ សេនាជនការពារបានប្រែក្លាយជាធាតុយ៉ាងសំខាន់នៃឧស្សាហកម្មទេសចរណ៍របស់យើង»។

អតីតកងអាវុធហត្ថ តង់សានី ដែលប្តូរមកធ្វើការក្នុងវិស័យទេសចរណ៍ទស្សនាសត្វព្រៃ លោក ឡូសឺរៀន ឡេហ្សឺ គិតថា ការអភិរក្សជ្រុលបំផ្លាញទេសចរណ៍ទៅវិញទេ។ លោក ឡូសឺរៀន ឡេហ្សឺ បរិយាយថា នៅក្នុងឧទ្យានជាតិដ៏ល្បីល្បាញនៃទ្វីបអាហ្វ្រិកខាងត្បូង អ្នកទស្សនាទាំងឡាយបានត្អូញត្អែរនឹងសម្លេងយន្តហោះឈ្លបការណ៍មើលសត្វ ដែលហោះក្រវែលចុះឡើង។

លោក ឡូសឺរៀន ឡេហ្សឺ បានបន្ថែមថា៖ «ប៉ុន្តែយើងបានឈ្នះការប្រឈមមុខ។ ខ្ញុំសូមអបអរសាទចំពោះអ្នកអភិរក្សសត្វព្រៃ។ មនុស្សកាន់តែច្រើនឡើងៗ យល់ថា វាមានសារៈសំខាន់ចាំបាច់ខានមិនបានក្នុងការអភិរក្សសត្វ ដើម្បីវិស័យទេសចរណ៍។ ប៉ុន្តែ គេត្រូវសាកល្បងការពារសត្វតាមរបៀបដែលកាន់តែឆ្លាតវាងវៃ»។

លោក ឡូសឺរៀន ឡេហ្សឺ វិនិច្ឆ័យថា ការបរបាញ់ខុសច្បាស់ មិនមែនជារឿងតែមួយដែលគំរាមកំហែងដល់សត្វព្រៃនោះទេ។

លោកលើកឡើងថា៖ «បញ្ហាគឺការសាងសង់កាន់តែច្រើនឡើងៗនូវហេដ្ឋារចនាសម្ពន្ធ ដើម្បីទទួលយកអ្នកមកទស្សនាសត្វនៅទ្វីបអាហ្វ្រិក។ រឿងនេះក៏បានបំផ្លាញបរិស្ថាន និងទីកន្លែងរបស់សត្វផងដែរ។ ដូច្នេះគេត្រូវតែគ្រប់គ្រងឲ្យបាននូវការវិវត្តន៍នេះ»៕


សត្វរមាសដែលត្រូវបានក្រុមព្រានព្រៃសម្លាប់។ រូបភាព៖ National Geographic



# SWEEP AWAY ជាក្បាច់រាំថ្មី បង្ហាញពី សក្តានុពលរបស់ស្ត្រី

**របាំសហស្សសម័យមួយ ដែលបានបង្ហាញក្នុងកម្មវិធីខួប៣០ ឆ្នាំនៃអង្គការបន្ទាយស្រី កាលពីពេលថ្មីៗនេះ បានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកទស្សនា។**


ឈុតរាំមួយនៅក្នុង Sweep Away ។ រូបភាព៖ សិល្បករថ្មីនៃកម្ពុជា

*ដោយ៖ ផល សុផានិត*

សំឡេងហោ៊គាំទ្រយ៉ាងរំពងបានបន្លឺឡើង បន្ទាប់ពីនារីបួននាក់ បានសម្តែងរបាំសហស្សសម័យមួយប្រភេទ ដែលមានលក្ខណៈខុសប្លែកពីគេ និងមិនធ្លាប់ឃើញកន្លងមក។ របាំមួយនេះ គេមិនសូវឃើញសម្តែងឡើយនៅក្នុងកម្មវិធីផ្សេងៗ ជាពិសេស នៅលើកញ្ចក់ទូរទស្សន៍នានា។ របាំមួយនេះ គឺជាប្រភេទរបាំដែលមានក្បាច់រាំសម័យថ្មី ប៉ុន្តែបង្កប់ន័យសិល្បៈខ្មែរបុរាណ ហើយវាគឺជាគំនិតច្នៃប្រឌិតរបស់សិល្បៈករខ្មែរសម័យថ្មី ចង់បង្ហាញភាពអង់អាចរបស់ស្ត្រី និងពង្រឹងនូវសិទ្ធិអំណាចរបស់ស្ត្រីតាមរយៈក្បាច់រាំនេះ។

កញ្ញា យុន ស្រីនាង ជាប្រធានក្រុមសិល្បករថ្មីនៃកម្ពុជាឬ New Cambodian Artists បានប្រាប់ឱ្យដឹងថា របាំសហស្សសម័យនេះមានឈ្មោះថា Sweep Away ។ កញ្ញាថា អត្ថន័យនៃរបាំនេះគឺចង់បង្ហាញពីការតាំងចិត្តមោះមុត របស់ស្ត្រីក្នុងការធ្វើកិច្ចអ្វីមួយ និងឆ្លុះបញ្ចាំងពីសក្តានុពលស្ត្រី ឱកាស និងសមត្ថភាពរបស់ស្ត្រីក្នុងការប្រឡូកក្នុងកិច្ចការងារសង្គម។

កញ្ញា យុន ស្រីនាង បន្ថែមថា របាំនេះធ្លាប់បានសម្តែងក្នុងវេទិកាអង្គការនានាបួនប្រាំដងរួចមកហើយ ហើយក៏ធ្លាប់ទទួលបានការកោតសរសើរ និងទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លោកស្រី ភឿង សកុណា ផងដែរ។

កញ្ញានិយាយថា របាំនេះមិនទាន់មានអ្នកណាចេះរាំនោះទេ មានតែក្រុមរបស់កញ្ញា ដែលមានសមាជិក៥នាក់នេះតែប៉ុណ្ណោះ។ កញ្ញាយុន ស្រីនាង រៀបរាប់ថា ការហាត់របាំនេះមានការលំបាកខ្លាំង ដោយសារតែការហាត់ត្រូវការកម្លាំងខ្លាំង។

ស្រីនាងបន្តថា៖«អ្វីដែលពួកខ្ញុំចង់ធ្វើ គឺចង់ជួយពង្រឹងសិទ្ធិស្ត្រី តាមរយៈការរាំរបស់ពួកខ្ញុំ។ ភ្លេងហ្នឹងគឺយើងប្រើទូទាំងជុំវិញពិភពលោកតែម្តង មានទាំងចិន តៃវ៉ាន់ អង់គ្លេស។ ខ្ញុំអត់ប្រកាន់ថាបទភ្លេងខ្មែរសុទ្ធ ទើបពួកខ្ញុំរាំនោះទេ។ គឺពួកខ្ញុំជ្រើសរើសទាំងអស់ ដោយហេតុថាសម័យឥលូវសម័យភាវូបនីយកម្ម អីចឹង ស្អីក៏អាចចូលគ្នាទៅវិញទៅមកបានដែរ។ ណាមួយរបាំសហសម័យហ្នឹងវាទូលាយ»។


ក្បាច់រាំស្តីអំពីកិច្ចការងារផ្ទះរបស់ស្ត្រីមេផ្ទះនៅប្រទេសកម្ពុជា។ រូបភាព៖ សិល្បករថ្មីនៃកម្ពុជា

របាំនេះទើបនឹងបង្កើតឡើងនៅឆ្នាំ២០១២ ដោយជនជាតិហូឡង់ម្នាក់ មានសមាជិករាំចំនួន៤នាក់ បង្កើតឡើង ដើម្បីលើកតម្កើងកិច្ចការងាររបស់ស្ត្រីមេផ្ទះ និងក្តីស្រមៃរបស់ពួកគាត់។

ចំណែកសមាជិកម្នាក់ទៀតរបស់ក្រុម សិល្បករថ្មីនៃកម្ពុជា អ្នកស្រី រឿន សារុន បានរៀបរាប់ថា ការហាត់របាំនេះមានការលំបាកខ្លាំង ដោយសារតែត្រូវប្រើបច្ចេកទេសច្រើនក្នុងការហាត់ ប៉ុន្តែដោយសាររបាំនេះជាប្រភេទរបាំមួយថ្មី មិនតែប៉ុណ្ណោះ វាបានបង្ហាញពីការលើកកម្ពស់ស្ត្រី ទើបអ្នកស្រី ព្យាយាមហាត់រហូតក្លាយជាអ្នករបាំសហស្សសម័យមួយរូប ។

អ្នកឯកទេសខាងរបាំប្រពៃណីរូបនេះ បានឱ្យដឹងថា របាំមួយនេះ មានលក្ខណៈខុសប្លែកពីរបាំបុរាណ ។ អ្នកស្រី រឿន សារុន បន្តថា លក្ខណៈរបស់របាំបុរាណមិនអាចបើកក្បាច់ឱ្យទូលាយបាននោះទេ ប៉ុន្តែរបាំប្រភេទថ្មីនេះ គេអាចបើកក្បាច់បានយ៉ាងទូលាយ និងអាចដាក់បានទាំងអារម្មណ៍ទាំងក្បាច់ ហើយថែមទាំងធ្វើឱ្យយើងមានចិត្តរំភើបជាមួយនឹងក្បាច់រាំនេះថែមទៀតផង។

អ្នកស្រី រឿន សារុន បន្ថែមថា ចំណុចដែលធ្វើឱ្យអ្នកស្រីជាប់ចិត្តក្នុងការហាត់របាំជាងគេ គឺ ត្រង់ឈុតមួយដែលបង្ហាញពីការស្រមើស្រមៃរបស់ស្ត្រី ថាពួកគាត់អាចមានសក្តានុពលធ្វើការងារផ្សេងក្រៅពីការបោសសម្អាតផ្ទះដូចបុរសដែរ ។

អ្នកស្រី សារុន៖ «ឈុតដំបូងដែលស្ត្រីគាត់ធ្វើការវក់វីជាមួយនឹងកិច្ចការក្នុងផ្ទះ ក៏ដូចជាខាងក្រៅ អីចឹងគាត់មានកិច្ចការច្រើនណាស់ មកដល់បោសសម្អាត មើលមានតែប៉ុណ្ណឹងរាល់ថ្ងៃ ប៉ុន្តែអ្វីដែលពួកគាត់គិតនឹកស្រម៉ៃរាល់ថ្ងៃ គាត់ចង់ធ្វើអ្វីឱ្យរំភើប ក្នុងចិត្តគាត់ចង់មានភាពសប្បាយ គាត់ចង់បង្ហាញទៅមនុស្សដទៃថា គាត់មិនមែនចេះតែប៉ុណ្ណឹងទេ គាត់មានក្តីស្រមៃគាត់ច្រើនណាស់»។

បើនិយាយអំពីការបង្ហាញពីសក្តានុពលរបស់ស្ត្រីវិញ ស្ត្រីវ័យ២៦ឆ្នាំរូបនេះ និយាយថា អ្នកស្រីមិនមែនបង្ហាញតែនៅក្នុងក្បាច់រាំនោះទេ ថែមទាំងការរស់នៅ អ្នកស្រីបានអនុវត្តក្នុងជីវិតប្រចាំថ្ងៃផងដែរ។ អ្នកស្រីថា ពិតមែនតែអ្នកស្ត្រី ជាស្ត្រីមេផ្ទះ ត្រូវចិញ្ចឹមបីបាច់ថែរក្សាកូនតូចក៏ដោយ តែអ្នកស្រី អាចចេញទៅធ្វើការរកលុយចិញ្ចឹមគ្រួសារផង និងមើលថែផ្ទះសម្បែងផងបានដែរ។

បន្ទាប់ពីទស្សនាការសម្តែងរបាំសហស្សសម័យនេះរួច កញ្ញា ហោ ស្រីទន់ បានប្រាប់ថា នេះជាលើកទីមួយហើយដែលកញ្ញាបានទស្សនារបាំនេះ។ កញ្ញានិយាយថា របាំនេះមានអត្ថន័យល្អ បង្ហាញពីការអប់រំទៅកាន់ស្ត្រីទូទៅថា ស្ត្រីត្រូវសម្លឹងមើលឱ្យបានឆ្ងាយ ប្រឡូកចូលសង្គមឱ្យបានច្រើន នោះពួកគាត់នឹងដឹងថា ខ្លួនឯងមានសក្តានុពលអាចធ្វើអ្វីបានទាំងអស់។

ស្របជាមួយគ្នានេះដែរ កញ្ញា ហោ ស្រីទន់ ចង់ឱ្យបុរសលើកទឹកចិត្តស្ត្រីឱ្យបានច្រើន ព្រោះថា ការលើកទឹកចិត្ត និងការឱ្យតម្លៃស្ត្រីពីបុរស វាពិតជាសំខាន់ណាស់ វានឹងអាចជំរុញឱ្យស្ត្រីកាន់តែមានចិត្តមោះមុត ដើម្បីការងារអ្វីមួយ ៕


សិល្បករថតរូបអនុស្សាវរីយ៍ជាមួយរដ្ឋមន្ត្រីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ រូបភាព៖ សិល្បករថ្មីនៃកម្ពុជា








# កាស៊ីណូមិនមែនសម្រាប់ពលរដ្ឋ

## ប៉ុន្តែពលរដ្ឋនៅតែមានអ្នកបាត់បង់ទ្រព្យសម្បត្តិដោយសារកាស៊ីណូ

**កាស៊ីណូដែលដំណើរការស្របច្បាប់ទាំងអស់នៅកម្ពុជាគឺមិនមែនសម្រាប់ទាក់ទាញពលរដ្ឋកម្ពុជាឡើយ ប៉ុន្តែ នៅតែមានសេចក្ដីរាយការណ៍មកជាហូរហែរថា ពលរដ្ឋនៅក្នុងស្រុកពួក គេនៅតែអាចចូលលេង និងបណ្ដាលឲ្យខាតបង់ទ្រព្យសម្បត្តិជាហូរហែរ។**

ពេលបច្ចុប្បន្ននេះ កាស៊ីណូ គឺមានច្រើន ប៉ុន្តែគោលដៅនៃការដាក់ឲ្យដំណើរការកាស៊ីណូទាំងនេះ គឺមិនមែនសំដៅសម្រាប់ទាក់ទាញប្រជាពលរដ្ឋកម្ពុជាឡើយ គឺសម្រាប់តែ បម្រើការកំសាន្ត និងទាក់ទាញភ្ញៀវទេសចរបរទេសតែប៉ុណ្ណោះ។ នេះបើតាមមន្ត្រីនៅក្រសួងទេសចរណ៍មួយរូបបានបញ្ជាក់។

មន្ត្រីដែលសុំមិនបញ្ចេញអត្តសញ្ញាណរូបនោះ បានអះអាងថា តាមច្បាប់ និងលិខិតបទដ្ឋាននានារបស់កម្ពុជា ពលរដ្ឋកម្ពុជាមិនអនុញ្ញាតិឲ្យចូលទៅលេងកាស៊ីណូទាំងនោះជាដាច់ខាត ហើយ ហេតុផលដែល អាជ្ញាធរអនុញ្ញាតិឲ្យកាស៊ីណូធ្វើប្រតិបត្តិការ គឺដោយសារតែកាស៊ីណូក៏ជាសេវាកម្សាន្តរបស់មនុស្សពេញវ័យ ហើយវាក៏ជាសេវាកម្មមួយសម្រាប់បម្រើភ្ញៀវទេសចរ។ លោកបានបន្តទៀត ថា នៅពេលបច្ចុប្បន្ននេះ មានប្រទេស និងដែនដីជាច្រើនដែលវិស័យទេសចរណ៍របស់គេកំពុងតែជោគជ័យ ដោយសារតែពួកគេដាក់ឲ្យប្រតិបត្តិការនូវសេវាកម្មកាស៊ីណូ ដូចជានៅទីក្រុងម៉ាកាវ ប្រទេសចិន នៅឡាសវេហ្គាស សហរដ្ឋអាមេរិក ជាដើម។

លោកបានបន្តទៀតថា នៅអាស៊ីអាគ្នេយ៍ក៏មានប្រទេសជាច្រើនដែលកំពុងតែដាក់ឲ្យដំណើរការនូវកាស៊ីណូទាំងនេះ។

លោកបានបន្តទៀតថា ជាទូទៅតាមកត្តាវប្បធម៌ និងសីលធម៌សង្គមកម្ពុជាមិនស្វាគមន៍កាស៊ីណូ ដោយសារតែវាជាប់ទៅនឹងបរិបទមួយគឺល្បែងស៊ីសង ដែលជាបម្រាមដ៏តឹងរ៉ឹងដែលសង្គមកម្ពុជា។ ល្បែងស៊ីសងគឺជាអំពើពាលាមួយដែលគ្រួសារ តែងតែប្រៀនប្រដៅកូនចៅមិនឲ្យប្រព្រឹត្តិល្បែងស៊ីសងនេះជាដាច់ខាត ប៉ុន្តែជាទូទៅនេះគឺជាការវិនិយោគ ហើយវាគឺជាសេវាកម្ម។ ម្យ៉ាងវិញទៀតនៅក្នុង បណ្ដាកាស៊ីណូទាំងនេះ ក្រៅពីមានល្បែងស៊ីសងហើយនោះ វានៅមានសេវាកម្មសណ្ឋាគារ ភោជនីយដ្ឋាន កន្លែងកំសាន្ត និង សេវាកម្មផ្សេងៗជាច្រើនទៀត សម្រាប់បម្រើភ្ញៀវទេសចរ។

ជុំវិញប្រតិបត្តិការរបស់បណ្ដាកាស៊ីណូទាំងនោះ ប្រជាពលរដ្ឋកម្ពុជាមួយចំនួនក៏ដឹងអំពីតួនាទី និង ស្គាល់ថា កាស៊ីណូ ជាអ្វី ហើយក៏ដឹងថា ទីនោះវាគឺជាកន្លែងដែលទាក់ទងនឹងអំពើអបាយមុខ ដែលសីលធម៌ និងអរិយធម៌សង្គមកម្ពុជាមិនឲ្យតម្លៃដែរ និង ក៏ដឹងថា ច្បាប់មិនអនុញ្ញាតឲ្យពលរដ្ឋទៅលេងដែរ ប៉ុន្តែជាទូទៅក្រៅពីភ្ញៀវទេសចរក៏នៅតែមានពលរដ្ឋកម្ពុជាមួយចំនួនបានចូលលេង ហើយ ធ្លាក់ខ្លួនវិនាសអន្តរាយទ្រព្យសម្បត្តិជាហូរហែរផងដែរ។

លោក ទិន ថានវីរៈ ជាប្រជាពលរដ្ឋវ័យ ៤៣ ឆ្នាំមួយរូប បានអះអាងថា ច្បាប់ពិតជាមិនអនុញ្ញាតឲ្យ ពលរដ្ឋកម្ពុជាចូលលេងមែន ប៉ុន្តែនៅពេលដែលពលរដ្ឋចូលលេងនៅទីនោះ ក៏មិនមានអ្នកណាមកសួរនាំ ឬមួយហាមថា អ្នកឯងមិនអាចចូលលេងបានទេនោះដែរ។

លោកបានបន្តទៀតថា ច្បាប់ និងបម្រាមមានតែនៅលើក្រដាសគេបិទជាប់ជញ្ជាំងទេ ប៉ុន្តែបើយើងយកលុយទៅលេង និង ចាយវាយនៅកន្លែងគេ ដូចជាមិនដែលឃើញបុគ្គលិក ឬ អ្នកបម្រើនៅក្នុង ហាងនោះគាត់មកសួរថា បងឯងខ្មែរមែន ឬអត់ឡើយ ដឹងតែមានលុយចូលទៅ គេញញឹមញញែម ស្វាគមន៍យើងហើយ។

លោកបានបន្តទៀតថា តាមលោកយល់គឺបម្រាមហាមឃាត់ពលរដ្ឋកម្ពុជាមិនឲ្យចូលលេងគឺមានបិទនៅគ្រប់កាស៊ីណូទាំងអស់ហ្នឹង ប៉ុន្តែពេលបើកទ្វារចូល ទៅបណ្ដាកាស៊ីណូគេអត់សួរអីទេ គេដឹងថា តែអ្នកឯកមានលុយដូរយកកាក់គេទៅលេង គឺអាចលេងបានហើយ។

> ពេលណាទៅបើកទ្វាកាស៊ីណូ សន្តិសុខគេបើកទ្វារស្វាគមន៍តែទាំងអស់ មិនដែលប្រកាន់ខ្មែរ ចិន វៀតណាម ឬ បរទេសស្អីទេ។ ឲ្យតែមកដល់បើកទ្វារហើយ។

លោកបានបន្តទៀតថា៖ « ខ្ញុំមិនមែនជាអ្នកលេងទេ តែឧស្សាហ៍ចេញចូលកាស៊ីណូជាច្រើនកន្លែង ដែរ ទើបដឹងស្ថានភាពទាំងនេះ។ ខ្ញុំចេញចូលចុះឡើងរាប់ភ្លេច តែមិនដែលមានសន្តិសុខ ឬអ្នកណាមកសួរនាំអីនោះទេ«។

លោកបានបន្តទៀតថា៖ «នរណាក៏ដូចជានរណា មិនថាបរទេសឬខ្មែរទេ ពេលណាទៅបើកទ្វាកាស៊ីណូ សន្តិសុខគេបើកទ្វារស្វាគមន៍តែទាំងអស់ មិនដែលប្រកាន់ខ្មែរ ចិន វៀតណាម ឬបរទេសស្អីទេ។ ឲ្យតែមកដល់បើកទ្វារហើយ»។

លោក រ៉េត តុលា ជាអ្នកបើករឺម៉កកង់ឌុប អាយុ ៣២ ឆ្នាំមួយរូប បានឲ្យដឹងថា លោកស្គាល់កាស៊ីណូ និងរីសត មួយដ៏ធំនៅក្នុងរាជធានីភ្នំពេញច្បាស់ណាស់ ព្រោះឧស្សាហ៍ដឹកភ្ញៀវចេញចូល។

កាស៊ីណូ និងរីសតដែល លោក រ៉េត តុលា បានស្គាល់នោះគឺគ្មានអ្វីក្រៅពីកាស៊ីណូ និងរីសត ណាហ្គានោះទ។ កាស៊ីណូនេះ គឺជាកាស៊ីណូស្របច្បាប់តែមួយគត់ដែលមាននៅរាជធានីភ្នំពេញ ហើយក៏ប្រហែលជា កាស៊ីណូដែលធំជាងគេនៅកម្ពុជាផងដែរ។ ទីនោះមានពីរអាគារធំៗ ដែលមានសេវាកម្មសណ្ឋាគារប្រណិត ភោជនីយដ្ឋានធំៗកម្រិតអន្តរជាតិ និង មានផ្លូវក្រោមដីដ៏ប្រណិតភ្ជាប់ពីអាគារទីមួយទៅអាគាមួយទៀត។

លោក រ៉េត តុលា បានឲ្យដឹងថា ភ្ញៀវទាំងខ្មែរទាំងបរទេសគឺតែងតែហៅដឹកទៅ កាស៊ីណូណាហ្គានេះទាំងថ្ងៃទាំងយប់ប៉ុន្តែភាគច្រើនគឺយប់។

លោកបានបន្តទៀតថា សម្រាប់ខ្មែរគឺភាគច្រើនកម្រហៅដឹកទៅណាស់ តែបើភ្ញៀវចិន ឬវៀតណាម គឺឧស្សាហ៍ហៅទាំងដឹកទៅ និងមក។

លោកបានបញ្ជាក់ថា៖ «បើខ្មែរ ភាគច្រើនគាត់តែងតែហៅតាមផាស អេប (Pass App) ពេលចេញមកវិញ ហើយភាគច្រើនមុខស្អុយ និងស្រវឹងតែម្ដង»។

អ្នកនាំសារ មិនអាចសុំទំនាក់ទំនងបុគ្គលិកផ្នែកទំនាក់ទំនងសាធារណនៅសណ្ឋាគារ និងរីសត ណាហ្គា នេះបានទេ ដើម្បីសុំព័ត៌មានទាក់ទងនឹងអតិថិជនជាជនជាតិខ្មែរ ដើម្បីឲ្យដឹងថា តើកាស៊ីណូមួយនេះ មានការគ្រប់គ្រង និងអនុវត្តនូវបម្រាមយ៉ាងណាសម្រាប់ជនជាតិខ្មែរ ខណៈដែលនៅខាងក្នុងនោះ គឺមានគ្រប់សេវាកម្មដែលរៀបរាប់ខាងលើ និងដើម្បីឆ្លើយតបតាមសេចក្ដីរាយការណ៍ព័ត៌មានតាមបណ្ដាគេហទំព័រ និងសារព័ត៌មានមួយចំនួន អំពីអំពើអសកម្ម គឺជាពិសេសចោរកម្មឆក់ និងប្លន់ ហើយលួចដោយសារតែពួកគេចាញ់ល្បែងពីទីនោះ។

លោក សេន ចាន់ណា ជាមន្ត្រីចូលនិវត្តន៍មួយរូប បានឲ្យដឹងថា លោកឃើញសណ្ឋាគារ និងរីសត ណាហ្គា នេះស្អាត ហើយចងចូលទៅសាកនឹងគេដែរ តែវាមិនហ៊ាន ដោយសារតែវាស្អាតពេក។ បើទោះបីជា លោកមិនដែលបានចូល គឺបានត្រឹមតែដើរហាត់ប្រាណនៅទីនោះ ក៏ពិតមែន ប៉ុន្តែលោកសង្កេតឃើញមានជនជាតិខ្មែរខ្លះចេញចូលជាញឹកញាប់ ។

លោកបានបន្តថា៖ «ខ្ញុំដើរហាត់ប្រាណនៅទីនេះម្ដងម្កាលជួនកាលក៏ឃើញឡានអ្នកនេះ ជួនអ្នកនោះចតហើយពេលខ្លះក៏ឃើញគេបើកឡានចេញពីទីនោះដែរ តែត្រង់ថា គេទៅធ្វើស្អីក៏មិនដឹងដែរ ពីព្រោះវាមិនដែលហ៊ានចូល»។

កាស៊ីណូនៅកម្ពុជាមានច្រើន ប៉ុន្តែនៅរាជធានីភ្នំពេញប្រហែលជាមានតែមួយទេ ក្រៅពីនោះ គឺភាគច្រើនស្ថិតនៅក្រៅរង្វង់ពីរាជធានីប្រហែលជា ២០០ គម ។ កាស៊ីណូ ច្រើនបំផុតនៅពេលបច្ចុប្បន្ននេះ គឺនៅទីក្រុងព្រះសីហនុ នៅតាមច្រកព្រំដែនកម្ពុជា និងថៃ ដូចជា នៅប៉ោយប៉ែត កោះកុង ឧត្តរមានជ័យ និង បណ្ដាព្រំដែនកម្ពុជា និងវៀតណាម ដូចជា នៅបាវិត និង ច្រកព្រំដែនមួយចំនួនទៀត។

តាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឲ្យដឹងថា នៅទូទាំងប្រទេសកម្ពុជាមានកាស៊ីណូដែលមានអាជ្ញាប័ណ្ណស្របច្បាប់គឺចំនួនប្រមាណជា ១៥០ កន្លែង ដោយភាគច្រើនបំផុតគឺនៅក្នុងខេត្តព្រះសីហនុ ។

ទាក់ទិននឹងកំណើនដ៏ច្រើននៃការសុំចុះបញ្ជីរបស់ក្រុមហ៊ុនប្រតិបត្តិករកាស៊ីណូទាំងនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិភាគ បានអះអាងថា សម្រាប់កម្ពុជានេះមិនមែនជាព័ត៌មានដែលគួរតែរីករាយនោះទេ។

ទោះបីវាមិនមែនសម្រាប់ប្រជាជនកម្ពុជា ប៉ុន្តែអាជីវកម្មកាស៊ីណូ វាអាចនឹងជាច្រកមួយសម្រាប់បម្រើបណ្ដាញសម្រាប់ការលាងលុយកខ្វក់ ការរត់ពន្ធមនុស្ស ឬជាប្រភពមួយដែលបង្កអសន្តិសុខសង្គមតាមរូបភាពផ្សេងៗ។

### ចំនួនកាស៊ីណូនៅកម្ពុជាកើនឡើងយ៉ាងគំហុក

តាមរបាយការណ៍ដែលមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្ដល់ឲ្យអ្នកសារព័ត៌មានកាលពីពេលថ្មីៗនេះ និងរបាយការណ៍កាលពីឆ្នាំទៅ ចំនួនកាស៊ីណូនៅកម្ពុជាមានការកើនឡើងយ៉ាងគំហុក ។

តាមសេចក្ដីរាយការណ៍ព័ត៌មាននៅឆ្នាំ ២០១៨ បានឲ្យដឹងថា នៅឆ្នាំ២០១៧ចំនួនកាស៊ីណូដែលមានអាជ្ញាប័ណ្ណសរុបទាំងអស់ចំនួន ៩៨ កន្លែង ហើយមកដល់ដើមឆ្នាំ២០១៩ មានសេចក្ដីរាយការណ៍ថា នៅមកដល់ដំណាច់ឆ្នាំ២០១៨ កន្លងទៅថ្មីៗនេះ កាស៊ីណូដែលមានអាជ្ញាប័ណ្ណទាំងអស់សរុបគឺចំនួន ១៥០ កន្លែង ។

របាយការណ៍ពីអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជានិយតករអាជីវកម្មកាស៊ីណូនៅក្នុងប្រទេស បានឲ្យដឹងថា ចំនួនស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មកាស៊ីណូនៅកម្ពុជាគឺមានការកើនឡើងប្រមាណជា ៥៣ ភាគរយ ហើយទីតាំងដែលមានការកើនឡើងខ្លាំងនោះ គឺនៅក្នុងខេត្តព្រះសីហនុ ។

ប្រភពដដែលបានបន្តថា នៅក្នុងចំណោម ១៥០ កាស៊ីណូ ដែលមានអាជ្ញាប័ណ្ណទាំងនោះ គឺនៅក្នុងខេត្តព្រះសីហនុ តែមួយគឺមានរហូតដល់ទី ៨៨ ទីតាំង។ នេះគឺជាព័ត៌មានទាក់ទងនឹងអាជ្ញាប័ណ្ណកាស៊ីណូ ប៉ុន្តែចំពោះប្រភពចំណូលពន្ធពីកាស៊ីណូទាំងនេះ មិនត្រូវបានគេចែករំលែក ប៉ុន្តែគេគ្រាន់តែដឹងថា សម្រាប់ឆ្នាំ២០១៩ នេះ ក្រសួងគ្រោងប្រមូលពន្ធពីកាស៊ីណូទាំងនេះឲ្យបាន ៥៦ លានដុល្លារ ៕

# ទឹកប្រាក់ជាង៦លានដុល្លារអាមេរិកត្រូវបានផ្តល់ដល់កម្មការិនីឆ្នាំ ២០១៨

ដោយៈ ឌី ដេន


កម្មការិនីថតរូបជាមួយនឹងសម្តេចតេជោ ហ៊ុន សែន។ រូបថត៖ ហេសប៊ុក

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈបេឡាជាតិរបបសន្តិសុខសង្គម បានចំណាយថវិការប្រមាណជាង៦,៥លានដុល្លារសហរដ្ឋអាមេរិកទៅដល់ស្ត្រីជាកម្មការិនីកម្មករក្នុងវិស័យកាត់ដេរ និងផលិតស្បែកជើង ចំនួនជាង៦៥ម៉ឺននាក់ ក្នុងរយៈពេលពេញមួយឆ្នាំ២០១៨កន្លងមកនេះ។

រដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង បានធ្វើរបាយការណ៍ជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីដើមខែមករានេះថា គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ស្ត្រីជាកម្មការិនីចំនួន ៦៥,០៥៤នាក់ បានសម្រាលកូនបានចំនួន ៦៥,៥៣៨នាក់ ដែលក្នុងនោះស្ត្រីចំនួន២៣៥នាក់ សម្រាលបានកូនភ្លោះពីរចំនួន៤៧០នាក់ ស្ត្រីចំនួន៥នាក់សម្រាលកូនភ្លោះបីបានចំនួន១៥នាក់។

លោកបន្តថា រាជរដ្ឋាភិបាលបានចំណាយថវិកាសរុបអស់ចំនួន ២៦.២១៣.៦០០.០០០ រៀល ឬ៦.៥៣លានដុល្លារអាមេរិក។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសផ្តល់នូវថវិកាជួយដល់ស្ត្រីជាកម្មការិនីសម្រាលកូនដោយកម្មការិនីសម្រាលកូនម្នាក់បានថវិកាចំនួន៤០ម៉ឺនរៀល និងពិនិត្យផ្ទៃពោះដោយឥតគិតថ្លៃ។ សម្រាលបានកូនភ្លោះ២ គឺទទួលបានថវិកា៨០ម៉ឺនរៀល ហើយបើសម្រាលបាន កូនគឺទទួលបានថវិកាចំនួន១លាន២សែនរៀល រួមនឹងប្រាក់ឧបត្ថម្ភចំនួន៥លានរៀលទៀតពី សម្តេចតេជោ និងភរិយា។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានជម្រាបផងដែរថា នៅពេលដ៏ខ្លីខាងមុខនេះ ចំពោះកម្មការិនីក្រីក្របំផុតនោះ គឺនឹងទទួលបាននូវប្រាក់ឧបត្ថម្ភប្រមាណ ៧៦០,០០០៛ ( ១៩០ដុល្លារ )។

អ៊ុក សមវិទ្យា នាយកបេឡាជាតិរបបសន្តិសុខសង្គម បានឲ្យដឹងថា នេះជាការផ្តល់ជូនកាដូពិសេសក្នុងការឆ្លើយតបទៅនឹងជីវភាពរស់នៅរបស់កម្មករជាស្ត្រីសម្រាលកូន ដែលកើតចេញពីគោលនយោបាយជាតិគាំពារសង្គម ក្នុងការលើកកម្ពស់សេវាគាំពារសង្គម និងការលើកកម្ពស់កំណើនប្រជាជនកម្ពុជា ក្នុងការដោះស្រាយនូវទុក្ខលំបាករបស់កម្មករ។

លោកបានបន្តទៀតថា ទាំងនេះគឺជាការឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការយកចិត្តទុកដាក់ខ្ពស់បំផុត ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចំពោះសុខុមាលភាព និងជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋកម្ពុជា ។

លោក ហ្វា សាលី ប្រធានសម្ព័ន្ធសហជីពជាតិ បានសាទរចំពោះការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ចំពោះកម្មការិនីសម្រាលកូន ប៉ុន្តែអ្វីដែលលោកចង់បានបន្ថែមសម្រាប់កម្មការិនីទៀតនោះគឺ ការថែទាំសុខភាព ជាពិសេសគឺកូនៗរបស់ពួកគាត់ នៅពេលឆ្លងទន្លេ។

# អត្រាស្លាប់ និងរបួសដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះមិនថយ មិនកើន

ដោយៈ ឌី ដេន


ជនរងគ្រោះដោយសារគ្រាប់មីននាពេលកន្លងមក។ រូបភាព៖ CMAG



ជនរងគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម មានចំនួន ៥៨នាក់ក្នុងឆ្នាំ២០១៨កន្លងទៅ ដែលតួលេខនេះមានចំនួនដូចគ្នាកាលពីឆ្នាំឆ្នាំ២០១៧។ យោងតាមរបាយការណ៍របស់អាជ្ញាធរមីនដែលចេញផ្សាយកាលពីដើមខែមករា។

របាយការណ៍បានឲ្យដឹងថា គិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ មានមនុស្សចំនួន១៣នាក់ ឬស្មើនឹង ២២ភាគរយ បានរងគ្រោះដោយសារមីន និង៤៥នាក់ ឬ ៧៨ភាគរយ ផ្សេងទៀត រងគ្រោះដោយសារសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។

ជនរងគ្រោះទាំង៥៨នាក់នោះ មានបុរសចំនួន៣៦នាក់ ( ៦២% ) ក្មេងប្រុសចំនួន ១៤នាក់ ( ២៤% ) ស្ត្រីចំនួន ៦នាក់ ( ១០% ) និងក្មេងស្រីចំនួន ២នាក់ ( ៤% )។

បើតាមរបាយការណ៍ដដែលនេះ បានបញ្ជាក់ថាជនរងគ្រោះទាំង៥៨នាក់នោះ មាន១០នាក់ ( ១៧% )បានស្លាប់ចំនួន១២នាក់ ( ២១% ) ពិការ និង៣៦នាក់ ( ៦២% ) ផ្សេងទៀតរបួស។

លោកទេសរដ្ឋមន្ត្រី លី ធុជ អនុប្រធានទី១ អាជ្ញាធរមីន បានក្រើនរំឮកដល់ប្រជាពលរដ្ឋទាំងអស់ដែលបាន នឹងកំពុងរស់នៅក្បែរតំបន់សង្ស័យថាមានមីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមឲ្យមានការប្រយ័ត្នខ្ពស់ និងត្រូវសហការជាមួយភ្នាក់ងារកម្ចាត់មីនដើម្បីផ្តល់នូវព័ត៌មានអំពីមីន។

ចាប់ពីឆ្នាំ១៩៩២ រហូតមកដល់ដើមខែមករា ឆ្នាំ២០១៩ កងកម្លាំងប្រតិបត្តិការបោសសម្អាត មីន MAG បានធ្វើសកម្មភាពបោសសម្អាត និងកម្ទេចគ្រាប់មិនទាន់ផ្ទុះបានចំនួន ២៤៩,០០០គ្រាប់ គ្រាប់មីនប្រឆាំងថ្មើរជើង និងប្រឆាំងរថក្រោះចំនួន ៧៨,០០០គ្រាប់។

កម្ពុជាបានចាប់ផ្តើមការងារបោសសំអាតមីនលក្ខណៈមនុស្សធម៌ ចាប់តាំងពីឆ្នាំ ១៩៩២ ដើម្បីធានាសុវត្ថិភាព និងផ្តល់ដីបង្កបង្កើនផលជូនប្រជាពលរដ្ឋ បន្ទាប់មកការបោសសំអាតមីនត្រូវបានធ្វើឡើង ដើម្បីសង្គ្រោះជីវិតកាត់បន្ថយគ្រោះថ្នាក់ និងគាំទ្រដល់កិច្ចអភិវឌ្ឍន៍នានា។

ដោយមានការជ្រោមជ្រែងយកចិត្តទុកដាក់យ៉ាងខ្លាំងពីរាជរដ្ឋាភិបាល និងសហគមន៍ផ្តល់ជំនួយប្រតិបត្តិករបោសសំអាតមីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម បានប្រតិបត្តិការបោសសំអាតមីនយ៉ាងសកម្ម ដែលជាលទ្ធផលគិតចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០១៧បានធ្វើការបោសសំអាតបានផ្ទៃដីចំនួនជាង១.៦៨០គីឡូម៉ែត្រក្រឡា ជូនប្រជាពលរដ្ឋសម្រាប់កសាងភូមិដ្ឋាន ធ្វើស្រែចម្ការ កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា និងបានរកឃើញនិងកម្ទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន១.០៤៧.៤៤៧ គ្រាប់ មីនប្រឆាំងរថក្រោះ ២៤.៦១៨ គ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាម ២.៧១៣.៦០៦គ្រាប់ ព្រមទាំងបានធ្វើឲ្យចំនួនជនរងគ្រោះធ្លាក់ចុះពី៤.៣២០ នាក់ ក្នុងឆ្នាំ១៩៩៦ មកត្រឹម៥៨នាក់ ក្នុងឆ្នាំ ២០១៧។

យោងតាមផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ឆ្នាំ ២០១៨-២០២៥ ដីសង្ស័យមានប៉ះពាល់ដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅមានប្រមាណជាង១៩៧០ គីឡូម៉ែត្រការ៉េ ក្នុងនោះដីប្រមាណ៨៧៧គីឡូម៉ែត្រការ៉េ ជាដីមានផលប៉ះពាល់ខ្ពស់ដោយសារមីន ដី ៨៩៩គីឡូម៉ែត្រការ៉េ ជាដីប៉ះពាល់ដោយគ្រាប់បែកចង្កោម និងដី ៣៣៣គីឡូម៉ែត្រការ៉េ ជាដីមានផលប៉ះពាល់ដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលមានតម្រូវការថវិកា ប្រមាណ៤០៦លានដុល្លារ សម្រាប់រយៈពេលចាប់ពីឆ្នាំ២០១៨ ដល់២០២៥។



# អូស្ត្រាលី រងអាកាសធាតុដ៏ក្តៅខ្លាំងមិនដែលធ្លាប់ជួប



សារណែនាំសុវត្ថិភាពរំឭកដល់អ្នកកំសាន្តតាមឆ្នេរសមុទ្រពីការកើនកំដៅខ្លាំង។ រូបភាព៖ ABC

ប្រទេសអូស្ត្រាលី នៅក្នុងខែមករា នេះកំពុងតែរងបាតុភូតអាកាសធាតុក្តៅខ្លាំង រហូតវាបានបង្កឲ្យងាប់សត្វព្រៃ ភ្លើងឆេះព្រៃ និងមានមនុស្សចូលមន្ទីរពេទ្យកាន់តែច្រើនឡើង។

ចាប់តាំងពីថ្ងៃទី ១៩ ខែមករា មក ការិយាល័យឧតុនិយមអូស្ត្រាលីបាននិយាយថា ជាមធ្យមអាកាសធាតុនៅអូស្ត្រាលីឡើងដល់៤០អង្សាសេ ខណៈកាលពីថ្ងៃទី១៨មករា សីតុណ្ហភាពនៅតំបន់ជាច្រើនបានឡើងដល់៤២អង្សាសេ។

អាកាសធាតុក្តីបំផុតពីមុននៅអូស្ត្រាលី គឺនៅខែមករាឆ្នាំ២០១៣ ដែលពេលនោះជាមធ្យមវាបានឡើងដល់៤០,៣អង្សាសេ។

លោក ប្លែរ ត្រេវីន មន្ត្រីនៅផ្នែកឧតុនិយមអូស្ត្រាលីបានអះអាងថា៖ «រលកកំដៅពេលនេះដូចគ្នានឹងឆ្នាំ២០១៣ ដែលក្តៅខ្លាំង និងអូសបន្លាយពេល»។

មួយផ្នែកធំនៃរដ្ឋញូវ សោតវេលកំពុងរងកំដៅចង់ឆេះ ខណៈសីតុណ្ហភាពក៏ឡើងនៅរដ្ឋក្វីនលែន, សោតអូស្ត្រាលី ,វិចធៀរៀ និងទឹកដីខាងជើង តែសីតុណ្ហភាពត្រូវរំពឹងថានឹងធ្លាក់នៅតំបន់ខាងត្បូង និងកណ្តាលនៅចុងសប្តាហ៍នេះ។

តំបន់ជាង១០នៅអូស្ត្រាលីក៏ជួបការឡើងកំដៅខ្លាំងមិនដែលធ្លាប់មានដូចជាក្រុងតាគូឡា នៅភាគខាងត្បូងឡើងដល់៤៩អង្សា កាលពីថ្ងៃអង្គារ និងផត អូហ្គូស្តា នៅអូស្ត្រាលីខាងត្បូងឡើងដល់៤៨,៩អង្សាសេ។

អាជ្ញាធរបានចេញការព្រមានអំពីសុខភាព និងអំពាវនាវប្រជាជនឲ្យនៅក្នុងផ្ទះហើយកាត់បន្ថយសកម្មភាពរាងកាយ ដោយបារម្ភបំផុតមនុស្សចាស់ អ្នកមានជម្ងឺរ៉ាំរ៉ៃ និងក្មេង។

ភ្លើងព្រៃជាច្រើនក៏ត្រូវបានគេរាយការណ៍ថាកើតមាននៅរដ្ឋវិចធីរៀ ,តាសម៉ានៀ និងញូវ សោត វេស កាលពីថ្ងៃព្រហស្បតិ៍ ដោយសារអាកាសធាតុក្តៅស្ងួត។សត្វប្រជៀវជាងពាក់កណ្តាលក៏ងាប់ដោយកំដៅ និងចំការបន្លែក៏ស្វិតក្រៀមក្រោមកំដៅថ្ងៃនៅញូវសោតវេល។

# អង្គការណាសានិង ប្រទេសចិនសហការគ្នា ស្រាវជ្រាវនៅឋានព្រះចន្ទ


យានអវកាសរបស់ចិន Chang'e-4។ រូបភាព៖ CHINESE STATE MEDIA

ទីភ្នាក់ងារអវកាសរបស់សហរដ្ឋអាមេរិក និងប្រទេសចិនកំពុងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងលើការរុករកឋានព្រះចន្ទ។

ថ្វីត្បិតតែទីភ្នាក់ងារអវកាសប្រទេសទាំងពីរសហការគ្នា តែអង្គការអវកាសអាមេរិកអះអាងថា កិច្ចសហប្រតិបត្តិការនេះ គឺត្រូវអនុវត្តក្នុងការប្រយ័ត្នប្រយែងខ្ពស់បំផុត។

អង្គការណាសា បានអះអាងថា ខ្លួនកំពុងធ្វើកិច្ចសហប្រតិបត្តិការនៅក្រោមក្របខ័ណ្ឌច្បាប់តឹងរ៉ឹងមួយ ដើម្បីការពារការផ្ទេរបច្ចេកវិជ្ជាឱ្យទៅប្រទេសចិន។

លោកថូម៉ាស ហ្សឺប៊ូកិន ដែលជាអនុប្រធាននៃអគ្គនាយកដ្ឋានបេសកកម្មវិទ្យាសាស្ត្ររបស់អង្គការណាសានិយាយនៅលើបណ្តាញសង្គម Twitter ថា៖ «ដោយមានការយល់ព្រមពីសភា ណាសា បានកំពុងពិភាក្សាជាមួយចិនដើម្បីស្វែងរកលទ្ធភាពអង្កេតមើលជើងសម្រាប់ចុះចតរបស់យានអវកាសស្រាវជ្រាវឋានព្រះចន្ទ Chang'e 4 ដោយប្រើឧបករណ៍របស់យានអវកាសរបស់អង្គការណាសា»។

លោកហ្សឺប៊ូកិនបានបញ្ជាក់ពីសេចក្តីថ្លែងការណ៍ស្រដៀងគ្នាមួយដែលបានធ្វើឡើង ដោយមេបញ្ជាការរងនៃកម្មវិធីរុករកឋានព្រះចន្ទរបស់ចិន លោកវូ យ៉ានហួ ( Wu Yanhua )។

លោកថា ណាសា បានចែករំលែកព័ត៌មានពីផ្កាយរណបរបស់អាមេរិកខណៈដែលចិនបានប្រាប់អាមេរិកអំពីរយៈទទឹងរយៈបណ្តោយ និងពេលវេលានៃការចុះចត «នៅក្នុងលក្ខខណ្ឌទាន់ពេលវេលា»។

ក្តីសង្ឃឹមគឺថា យានស្រាវជ្រាវឋានព្រះចន្ទ ( LRO ) របស់អង្គការណាសាអាចឃ្លាំមើលការចុះចតជាប្រវត្តិសាស្ត្ររបស់យានអវកាសចិនកាលពីថ្ងៃទី ៣ ខែមករា។

ណាសា បានផ្តល់ផ្លូវហោះហើរតាមផែនការរបស់យាន LRO ដល់ចិន ប៉ុន្តែយានអវកាសអាមេរិកមិនបានស្ថិតនៅចំកន្លែងត្រឹមត្រូវ និងចំពេលត្រឹមត្រូវនោះទេ។

# ទឹកកកនៅទ្វីបអង់តាក់ទិករលាយលឿនជាងមុន៦ដង គិតចាប់តាំងពីឆ្នាំ១៩៧៩

ក្រុមអ្នកវិទ្យាសាស្ត្របានព្រមានថា ការឡើងកម្តៅសកលលោកគឺកំពុងធ្វើឱ្យរលាយទឹកកកនៅទ្វីបអង់តាក់ទិកលឿនជាងពេលណាៗទាំងអស់ ពោលគឺរលាយលឿងនជាងមុនប្រហែលជា ៦ ដងក្នុងមួយឆ្នាំធៀបនឹង ៤០ ឆ្នាំមុន ដោយនាំឱ្យកម្រិតទឹកសមុទ្រកើនឡើងខ្ពស់។

អ្នកវិទ្យាសាស្ត្រអះអាងថា ការរលាយនៅតំបន់អង់តាក់ទិកបានបង្កើនកម្ពស់ទឹកសមុទ្រជាង ១,៤ សង់ទីម៉ែត្ររវាងឆ្នាំ ១៩៧៩ និងឆ្នាំ ២០១៧។

លោកអេរិក រីកណូត ( Eric Rignot ) ប្រធាននៃវិទ្យាសាស្ត្រប្រព័ន្ធផែនដីនៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ាបាននិយាយថា ល្បឿននៃការរលាយត្រូវគេរំពឹងថានឹងនាំទៅរកការកើនឡើងកម្ពស់ទឹកសមុទ្រក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។

លោករីកណូតថា៖ «ខណៈដែលផ្ទាំងទឹកកកអង់តាក់ទិកបន្តរលាយបាត់ទៅ យើងរំពឹងថាកម្ពស់ទឹកសមុទ្រនឹងកើនឡើងរាប់ម៉ែត្រពីទ្វីបអង់តាក់ទិកនៅប៉ុន្មានសតវត្សរ៍ខាងមុខ»។

ការសិក្សាបង្ហាញថា ការកើនឡើងកម្ពស់ទឹកសមុទ្រ ១,៨ ម៉ែត្រនៅត្រឹមឆ្នាំ ២១០០ ដូចដែលអ្នកវិទ្យាសាស្ត្រមួយចំនួនបានព្យាករណ៍ក្នុងករណីដ៏អាក្រក់បំផុតនោះ នឹងពន្លិចទីក្រុងឆ្នេរសមុទ្រជាច្រើន ដែលជាលំនៅដ្ឋានរបស់មនុស្សរាប់លាននាក់នៅជុំវិញពិភពលោក។

# ការបំពុលខ្យល់ បានកើតមាន ហើយនៅទីក្រុង បាងកក

ខណៈទីក្រុងបាងកកកំពុងតែរងនូវការបំពុលខ្យល់ដល់កម្រិតអាចប៉ះពាល់ដល់សុខភាព ហើយនោះ ប្រទេសថៃបានប្រើយន្តហោះបង្កើតភ្លៀង និងកាណុងបាញ់ទឹកដើម្បីដោះស្រាយផ្សែងអ័ព្ទ។

ថៃបានបញ្ជូនចេញយន្តហោះបង្កើតពពកបង្កទឹកភ្លៀង ក្នុងកិច្ចខិតខំមួយដើម្បីដោះស្រាយការបំពុលអាកាសធាតុដ៏អាក្រក់នៅក្នុងរាជធានីបាងកក។

បច្ចេកវិទ្យាកែប្រែអាកាសធាតុ ដោយបាចសារធាតុគីមីដើម្បីអោយករជាពពកបង្កើតភ្លៀងនេះ ជាគំនិតផ្តួចផ្តើមឡើងដោយអតីតស្តេចថៃដើម្បីជួយនាំទឹកភ្លៀងដល់កសិករថៃ តែពេលនេះត្រូវបានគេប្រើសំរាប់ជួយអ្នកក្រុងបាងកក។

ស្ថានភាពដ៏អាក្រក់នេះ ពលរដ្ឋថៃនៅបាងកកបានជួបកាលពីសប្តាហ៍មុន ខណៈអង្គការបរិស្ថានពិភពលោកGREENPEACEបាននិយាយថា ក្រុងបាងកកឥឡូវជាទីក្រុងដែលមានខ្យល់អាកាសកខ្វក់ពុលបំផុតទី១០លើលោក។

មូលហេតុដែលនាំឲ្យមានអ័ព្ទជាប្រចាំនេះ ដោយសារ ការបញ្ចេញផ្សែងពីយានយន្ត ការដុតព្រៃ ដុតស្មៅ ធ្វើចំការនៅក្រៅក្រុង និងការបំពុលចេញមកពីបណ្តារោងចក្រ។

ការមិនសប្បាយចិត្តពីសាធារណជនអំពីខ្យល់អាកាសនេះ ត្រូវបានបញ្ចេញលើបណ្តាញសង្គម និងទូរទស្សន៍ថៃ។

# គ្រូអប់រំជំនឿ យកពេលសំណាក់ធម៌ រិះគិតអំពីផ្លូវវិញ្ញាណ

ក្រុមគ្រូអប់រំជំនឿចំនួន១៨នាក់នៃព្រះសហគមន៍បាត់ដំបងក្រុង បានជួបជុំគ្នាសំណាក់ធម៌ដើម្បីរិះគិតអំពីជីវិតខាងផ្លូវវិញ្ញាណកាលពីថ្ងៃទី៧មករា នៅព្រះវិហារសន្តីតេរេសា នៃព្រះកុមារយេស៊ូ ដែលស្ថិតនៅក្នុងភូមិ រង្វាន់លិច ឃុំចំណោម ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ កម្មវិធីសំណាក់ធម៌នេះ ណែនាំដោយលោកបូជាចារ្យ យ៉ូហាន អ៊ីវ៉ាន អាស្លី។

*ដោយ៖ រឿន ស្រីម៉ាច*

អ្នកស្រី ស្រី សុជុំ ជាសមាជិកគណៈអប់រំជំនឿព្រះសហគមន៍បាត់ដំបង ក្រុង បានរៀបរាប់ថា ជារៀងរាល់ឆ្នាំ គឺតែងតែមានកម្មវិធីសំណាក់ធម៌ពីរដងសម្រាប់គ្រូអប់រំជំនឿ និងសិស្សដែលមកទទួលអប់រំជំនឿ។

អ្នកស្រីបន្តថា៖ «កម្មវិធីសំណាក់ធម៌នេះមានសារៈសំខាន់ណាស់ព្រោះជាពេលវេលាមួយដែលឲ្យយើងម្នាក់ៗមានពេលវេលាស្ងប់ស្ងាត់ និងរិះគិតអ្វីល្អៗ ជាពិសេស បានទទួលការអប់រំពីសំណាក់លោកបូជាចារ្យ និងបងស្រីជាអ្នករៀបចំកម្មវិធី ព្រមទាំងជំរុញយើងកាន់តែមានកម្លាំងខាងផ្លូវវិញ្ញាណ ដើម្បីបន្តការប្រកាសដំណឹងល្អ»។

ចំពោះ ស្រី សុជុំ ផ្ទាល់ ជាអ្នកណែនាំជំនឿម្នាក់ដែរនោះ បន្តថា៖ «ខ្ញុំសប្បាយចិត្តរាល់ពេលដែលមានកម្មវិធីសំណាក់ធម៌ ឬកម្មវិធីអធិដ្ឋានជាមួយគ្នាបែបនេះព្រោះថាយើងមានឱកាស់បាននៅជាមួយគ្នាជាក្រុម អធិដ្ឋានជាមួយគ្នា និងចែករំលែកអ្វីដែលយើងមាន ហើយលើសពីនេះ គឺខ្ញុំតែងតែទទួលបាននូវចិត្តជ្រះថ្លា និងមានគំនិតថ្មីៗដើម្បីត្រៀមសម្រាប់ទៅបង្រៀនដល់ប្អូនៗដែលមកទទួលការអប់រំជំនឿផងដែរ»។

ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងតែងតែយកចិត្តទុកដាក់ជាខ្លាំង អំពីការអប់រំ បន្តជំនឿ ព្រោះជាផ្នែកមួយដែលនាំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់លាន់ឮឡើង និងបន្តរក្សាជំនឿឲ្យរឹងមាំ ជាពិសេស ធ្វើឲ្យព្រះសហគមន៍កាន់តែរីកចម្រើនឡើង។ កិច្ចការអប់រំជំនឿគឺជាការបញ្ជូនបន្តជំនឿ និងនាំដំណឹងល្អសម្រាប់មនុស្សទាំងឡាយដែលចង់ស្គាល់ព្រះយេស៊ូ។

នៅក្នុងឆ្នាំ២០១៩នេះ ព្រះសហគមន៍កាតូលិកព្រះជាម្ចាស់លើកព្រះនាងម៉ារី ឡើងស្ថានបរមសុខក្រុងបាត់ដំបង មានសិស្សដែលមកទទួលការអប់រំជំនឿចំនួន២៥០នាក់ និងគ្រូ២១នាក់ ដែលមានបែងចែកជា១២ថ្នាក់តាមកម្រិតផ្សេងៗគ្នា៕





*ការចែករំលែកជាក្រុមរិះគិតអំពីការបង្រៀនអប់រំជំនឿដល់មនុស្សពេញវ័យ។ រូបភាព៖ ព្រះសហគមន៍បាត់ដំបង*








*យុវជនកាតូលិកនៅព្រះសហគមន៍ភូមិភាគកំពង់ចាម ចូលរួមវគ្គតម្រង់ទិសសម្រាប់អនាគតនៅព្រះសហគមន៍ចំលាក់។ រូបភាព៖ រិទ្ធី*

# ព្រះសហគមន៍កាតូលិក ជួយតម្រង់ទិស យុវជនក្នុងការសិក្សាឱ្យបានជោគជ័យ

*ដោយ៖ រឿន ស្រីម៉ាច*

ដើម្បីបង្ហាញផ្លូវយុវជនកាន់តែចាប់អារម្មណ៍អំពីការសិក្សា និងដើម្បីចូលរួមចំណែកក្នុងវិស័យអប់រំឲ្យកាន់តែរីកចម្រើនឡើង ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានរៀបចំកម្មវិធីសិក្ខាសាលាមួយស្ដីអំពី «ភាពជោគជ័យក្នុងការសិក្សា» សម្រាប់យុវជនយុវនារីប្រមាណជា១៥០នាក។

សិក្ខាសាលានេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៧ មករា ឆ្នាំ២០១៩ នៅព្រះវិហារចម្លាក់ ឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

តាមប្រសាសន៍របស់លោកបូជាចារ្យ ផាន បូរី ជាបូចារ្យទទួលបន្ទុកនៅក្នុងព្រះសហគមន៍ចម្លាក់បានឲ្យដឹងថា ក្នុងកម្មវិធីសិក្ខាសាលានេះ គឺមាន៣ចំណុចសំខាន់ៗ ដើម្បីជួយដល់សិក្ខាកាមរិះគិត ដែលមានដូចជា «អ្វីជាគោលដៅនៃជីវិត?» មួយវិញទៀត «ត្រូវមានគំនិតក្នុងការគិតគូរពិចារណាក្នុងជីវិត» និងចំណុចមួយទៀតគឺ «ការវិនិយោគខ្លួនឯង»។

លោក បូរី បន្ថែមទៀតថា ក្នុងសិក្ខាសាលានេះ គឺអ្នកចូលរួម ជាសិស្សថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ ចំពោះប្អូនៗថ្នាក់ទី១២ ត្រូវបានផ្ដោតសំខាន់ ព្រោះគេត្រូវត្រៀមខ្លួនឲ្យបានល្អ ហើយត្រូវមានគោលដៅក្នុងការសិក្សាឲ្យបានត្រឹមត្រូវ គឺ «រៀនដើម្បីសំរេចក្ដីស្រមៃដែលខ្លួនចង់ក្លាយជាអ្វីមួយនៅថ្ងៃអនាគត មិនមែនរៀនដើម្បីតែចេញផុតពីផ្ទះនោះទេ»។

ក្នុងកម្មវិធីសិក្ខាសាលានេះ ណែនាំដោយអង្គការគ្រួសារសន្តិភាព ព្រមទាំងមានសក្ខីភាពរបស់លោកគ្រូ២រូបដែលធ្លាប់ជោគជ័យក្នុងការសិក្សានៅភូមិចម្លាក់តែម្ដង។





*សកម្មភាពរបស់យុវជនក្នុងសិក្ខាសាលាតម្រង់ទិសសិក្សា។ រូបភាព៖ រិទ្ធី*



*អធិដ្ឋានតាមបែបតេហ្សេដើម្បីបិទសិក្ខាសាលាតម្រង់ទិសសម្រាប់យុវជន។ រូបភាព៖ រិទ្ធី*

> “ ចំពោះថាការទទួលបាន និងអនុវត្តន៍បានប៉ុណ្ណា គឺអាស្រ័យទៅលើខ្លួនយើងម្នាក់ៗ ព្រោះអនាគតគឺស្ថិតនៅលើដៃរបស់យើង។

លោកបូជាចារ្យបូរី បន្ថែមទៀតថា យុវវ័យសម័យនេះ បើនៅតាមជនបទ បណ្ដាខេត្តមួយចំនួន គឺភាគច្រើនបោះបង់ការសិក្សា ដើម្បីទៅធ្វើការរកលុយ។ លោកទទួលស្គាល់ថា តម្រូវការក្នុងគ្រួសារនីមួយៗសំខាន់។ តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺចំណេះដឹង។ ប្រសិនបើយើងមានចំណេះដឹង គឺមិនខ្វះផ្លូវដើម្បីទទួលបានការងារនោះទេ។

លោកបានបញ្ជាក់ថា ហេតុនេះ យុវជនគឺជាអ្នកជំនាន់ក្រោយ ហើយការងារជាច្រើនកំពុងរង់ចាំពួកគេ។ ដូច្នេះ ពួកគេត្រូវមានគោលដៅឲ្យច្បាស់ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានអនាគតល្អ នៅក្នុងសង្គម។

តាមរយៈ ព្រះសហគមន៍គឺមានតែការជំរុញ និងលើកទឹកចិត្តឲ្យយុវជនខិតខំរៀន និងមានកម្មវិធីផ្សេងៗជាជំនួយដល់ស្មារតី។

លោកសង្កត់ធ្ងន់ថា៖ «ចំពោះថាការទទួលបាន និងអនុវត្តន៍បានប៉ុណ្ណា គឺអាស្រ័យទៅលើខ្លួនយើងម្នាក់ៗ ព្រោះអនាគតគឺស្ថិតនៅលើដៃរបស់យើង»។

យុវជនដែលចូលរួមក្នុងកម្មវិធីសិក្ខាសាលានេះ គឺមានមកពីព្រះសហគមន៍កោះរការ មណ្ឌលយុវជនប្រុស និងស្រីកំពង់ចាម សួង ផ្គាដូង អូររាំងឪ និង ចម្លាក់។

ក្រោយពេលបញ្ចប់កម្មវិធីសិក្ខាសាលានេះ ក៏មានកម្មវិធីអធិដ្ឋាន តេហ្សេរួមគ្នាផងដែរ ដើម្បីសូមព្រះវិញ្ញាណបំភ្លឺផ្លូវដល់សិក្ខាកាមទាំងអស់ឲ្យទទួលបានជោគជ័យក្នុងការសិក្សា៕

# លោកអភិបាលអូលីវីយេ៖ ក្រុមគ្រួសារ ជាសញ្ញាសម្គាល់ អំពីព្រះហឫទ័យមេត្តា របស់ព្រះជាម្ចាស់ក្នុងសង្គម

ក្នុងឆ្នាំ ២០១៩ ខាងមុខនេះ តើយើងត្រូវធ្វើអ្វីខ្លះដើម្បីឲ្យយើងឃើញនូវអ្វី ៗដ៏ល្អប្រសើរថែមទៀត និងអ្វី ៗថ្មីកើតមក ? នៅខែមិថុនា ២០១៩ យើងនឹងចូលក្នុងឆ្នាំចុងក្រោយដែលឧទ្ទិសសម្រាប់ក្រុមគ្រួសារ គឺយើងនឹងចាត់ចែងឲ្យមានការប្រជុំយ៉ាងធំក្នុងភូមិភាគ។ នៅខែតុលា យើងហ្នឹងជាខែពិសេស គឺយើងនឹកគិតអំពីការប្រកាសដំណឹងល្អ តាមការណែនាំរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ។ ក្នុងខែនោះយើងនឹងរិះគិតអំពី ក្រុមគ្រួសារ ជាសញ្ញាសម្គាល់អំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់ក្នុងសង្គម។ នេះជាប្រសាសន៍របស់លោក អូលីវីយេ ជ្មីតអីស្លែរ៉ែ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្នុងពេលជួបជុំជាមួយគ្រប់តំណាងគ្រីស្តបរិស័ទនៃព្រះសហគមន៍ រួមនិងទាំងលោកបូជាចារ្យ បព្វជិត បព្វជិតានៃភូមិភាគភ្នំពេញក្នុងឱកាសបុណ្យព្រះជាម្ចាស់សម្ដែងអង្គឲ្យមនុស្សលោកស្គាល់ កាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០១៩ កន្លងទៅ។

*ដោយៈ លី សុវណ្ណា*

បើតាមលោកអភិបាលអូលីវីយេ បានលើកឡើងឲ្យដឹងថា ព្រះជាម្ចាស់សម្ដែងព្រះហឫទ័យប្រណីសន្ដោសសព្វថ្ងៃ ជាងកាលពីសម័យមុនទាំងអស់ តាមរយៈភូមិយើង តាមរយៈក្រុមគ្រួសារយើង និងតាមរយៈការរស់នៅរបស់យើងម្នាក់ៗផ្ទាល់ខ្លួន។ ក្នុងឱកាសនោះដែរ លោកអភិបាលក៏បាន រំលឹកនូវបទពិសោធន៍នានាដែលបានបង្ហាញពីវត្តមានពិតប្រាកដរបស់ព្រះជាម្ចាស់ តាមរយៈសកម្មភាពរបស់ព្រះសហគមន៍ក្នុងឆ្នាំកន្លងទៅ ជាពិសេសក្នុងរដូវបុណ្យព្រះយេស៊ូប្រសូតឆ្នាំ២០១៨ ដែលលោកបានធ្វើដំណើរ តាមទីកន្លែងនីមួយៗជួបមនុស្សរាប់ម៉ឺននាក់ ដែលមកពីសាសនាផ្សេងៗ ទាំងចាស់ទាំងក្មេង។

លោកអភិបាលបន្តថា៖ «ខ្ញុំអរព្រះគុណព្រះជាម្ចាស់រួមជាមួយបងប្អូនសម្រាប់ឆ្នាំកន្លងទៅនេះ ចំពោះអ្វីៗដែលមានតម្លៃដ៏ប្រសើរក្នុងព្រះសហគមន៍របស់យើង។ បងប្អូនម្នាក់ៗអាចបន្ថែមបទពិសោធន៍របស់ខ្លួនដែលបានចែករំលែកជាមួយបងប្អូនឯទៀតៗ។ បងប្អូនម្នាក់ៗក៏អាចបន្ថែមនូវការខកចិត្តខ្លះ និងទុក្ខព្រួយខ្លះដែរ។ ដោយសារតែព្រះជាម្ចាស់ប្រសូតជាមនុស្ស ព្រះអង្គនឹងប្រទានអត្ថន័យថ្មីៗឲ្យបងប្អូន»។



*រូបភាព៖ ស៊ីអេសស៊ី*

លោកបន្តថា៖ «ក្នុងរាត្រីបុណ្យព្រះយេស៊ូប្រសូតតក៏មានកូនង៉ែត ទទួលអគ្គសញ្ញាជ្រមុជទឹក។ យើងដាក់កូនរបស់ខ្លួនក្នុងស្នូកសត្វ ពិតជាសញ្ញាមួយដ៏ល្អប្រពៃ។ ក្រុមគ្រួសារជាសង្គមមនុស្សមួយ ហើយក៏ជាព្រះសហគមន៍ដែរ។ យើងគួរថែរក្សារបៀបដ៏ល្អសម្រាប់ការរស់នៅ ដូចក្រុមគ្រួសារដ៏វិសុទ្ធ ដែលមានព្រះកុមារយេស៊ូ ព្រះនាងម៉ារី និងលោកយ៉ូសែប»។

ជាមួយគ្នានេះ លោកអភិបាលក៏បានបង្ហាញ នូវគន្លឹះចំនួន៩ចំនុច សម្រាប់កិច្ចការដែលត្រូវបំពេញក្នុងឆ្នាំ២០១៩ គឺចិត្តស្មោះស្ម័គ្រ សេចក្ដីស្រលាញ់ដែលឲ្យ និងទទួលពីគេ សេចក្ដីសង្ឃឹមជីវិត សេចក្ដីថ្លៃថ្នូរ ការចងចាំ ការកែប្រែចិត្តគំនិត គ្រួសារ និងសេចក្ដីសុខសាន្ត។

លោកបានបញ្ជាក់ក្នុងពេលនោះដែរថា៖ «កុមារា កុមារី ទារកដែល ឪពុកម្ដាយលះបង់ចោលតាមចិញ្ចើមថ្នល់ ដោយគ្មានគ្រួសារ ដោយគ្មាននរណាស្រឡាញ់។ វាបានរកឃើញក្រុមគ្រួសារដ៏កក់ក្ដៅដែលស្រឡាញ់វា នៅក្នុងក្រុមគ្រួសារ



*លោក អូលីវីយេ ជ្មីតអីស្លែរ៉ែ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ រូបភាព៖ ស៊ីអេសស៊ី*

បងស្រីមេត្តាករុណានៃម្ដាយតេរេសា។ នេះក៏ជាព្រះសហគមន៍យើងដែរ។ ជាមហាគ្រួសារដូចគ្រួសារដ៏វិសុទ្ធ»។

លោកបានបន្តថា៖ «នៅបុណ្យព្រះយេស៊ូប្រសូត មានសហគមន៍ជាច្រើនសុខចិត្តប្រមូលចាស់ទុំ ដើម្បីចែករំលែកអំណរសប្បាយ និងបាននាំឲ្យចាស់ទុំមានសេចក្ដីសុខ និងភាពកក់ក្ដៅ។ យើងសប្បាយចិត្តដោយឃើញយុវជនបម្រើចាស់ទុំ និងអង្គុយជិតគាត់ និងស្ដាប់គាត់។ ក្នុងឆ្នាំនេះ ជាឆ្នាំនៃក្រុមគ្រួសារ យើងត្រូវសុខចិត្តបើកកន្លែងទទួលស្វាគមន៍ចាស់ទុំ ដើម្បីឲ្យឫសរបស់យើងចាប់( ជាប់ )នឹងប្រវត្តិសាស្ត្រ និងដើម្បីឲ្យមនុស្សគ្រប់ជំនាន់ ចេះស្ដាប់គ្នាទៅវិញទៅមក និងយល់ចិត្តគ្នាផងដែរ»។

ចំពោះការកសាងសេចក្ដីសុខសាន្តវិញ លោកអភិបាលអូលីវីយេបានលើកឡើងថា“នៅភូមិគ្រឹះបងស្រីមេត្តាករុណា នៃអ្នកម្ដាយតេរេសា មានបងប្អូនអ៊ីស្លាមបរិស័ទ និងពុទ្ធបរិស័ទ មកចូលរួមអបអរសាទរ និងកំសាន្តក្នុងពិធីបុណ្យព្រះយេស៊ូប្រសូត។ មួយទៀតមាន ព្រះសង្ឃ និងគណៈកម្មាធិការ អាចារ្យវត្ត នៅភូមិចំការទៀងបាននិមន្ត និងអញ្ជើញមកសួរសុខទុក្ខ និងជូនពរដល់ព្រះសហគមន៍កាតូលិកយើងក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត។ បុណ្យព្រះយេស៊ូប្រសូត គឺពិតជាព្រះជាម្ចាស់ត្រាស់ហៅយើងយ៉ាងអស្ចារ្យដើម្បីកសាង «សន្តិភាព»។

នៅក្នុងឱកាសនោះដែរ លោកអភិបាលបានរំលឹកដល់អ្នកចូលរួមទាំងអស់ថា យើងត្រូវធ្វើជាគ្រួសារដ៏វិសុទ្ធដែលបង្ហាញខ្លួន និងឲ្យគេស្រឡាញ់។ យើងត្រូវធ្វើជាពពួកទេវទូតដែលនាំសេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់ មកដល់ផែនដីយើងនេះ។ យើងត្រូវទៅជាធូប ដែលនាំសេចក្ដីត្រេកអរ។ ផ្កាយនៅតែរះឡើងក្នុងទីងងឹតក្នុងភាពងងឹត។ យើងត្រូវទៅជាស្នូកសត្វដែលមានជីវិត ដើម្បីទទួលព្រះកុមារយេស៊ូ និងហុចឲ្យមនុស្សទាំងអស់អាចមកគោរពថ្វាយបង្គំព្រះអង្គ។ យើងជាស្នូកសត្វដ៏ល្អប្រសើរក្នុងពិភពលោកក្នុងឆ្នាំ ២០១៩ នេះ! ដូច្នេះមនុស្សលោកនឹងសប្បាយរីករាយ និងចូលរួមជាមួយយើងព្រមទាំងរកឃើញព្រះសហគមន៍របស់យើងទុកជាមហាគ្រួសារដែលស្រឡាញ់គេ និងទទួលស្វាគមន៍គេយ៉ាងកក់ក្ដៅ!៕



# ពេជ្រ សំនៀង៖ «ជីវិតគ្មានគោលដៅ តែព្រះជាម្ចាស់ដឹកដៃខ្ញុំដើរហូតមក»

គ្រួសារជាទ្រនំដែលកក់ក្ដៅ ទោះបីជាជម្រកនោះតូចលំបាករស់នៅក្ដី តែឪពុកម្ដាយគឺជារបាំងមួយដ៏កក់ក្ដៅសម្រាប់កូន ៗ។ ក្នុងវ័យក្មេងខ្ចី កុមារីម្នាក់បានបាត់បង់ម្ដាយជាទីស្រឡាញ់របស់ខ្លួន ហើយឪពុកក៏បានបោះបង់នាងចោលទៀត។ ជីវិតជាកូនកំព្រាមិនងាយស្រួលឡើយ ព្រោះត្រូវប្រឈមមុខនឹងរឿងរ៉ាវជាច្រើននៅក្នុងជីវិត។ នាងបានតស៊ូរហូតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ហើយការលំបាកនេះបានធ្វើឲ្យនាងក្លាយជាមនុស្សរឹងមាំមួយរូប។ នេះជាឆាកជីវិតមួយរបស់យុវតីម្នាក់ឈ្មោះ ***ពេជ្រ សំនៀង***។ តើមានកត្តាអ្វីខ្លះដែលជំរុញនាង ? ***រឿន ស្រីម៉ាច*** នឹងបរិយាយអំពីជីវិតរបស់សំនៀងដូចតទៅនេះ។



*ពេជ្រ សំនៀង។ រូបភាព៖ សហការី*

សំនៀងជាក្មេងស្រីម្នាក់ដែលកើតចេញពីគ្រួសារពុទ្ធបរិស័ទហើយជាកូនស្រីទោលក្នុងគ្រួសារដែលមានស្រុកកំណើតនៅក្នុងភូមិតាទែន ឃុំសំពោងក្រោម ស្រុកបន្ទាយមាស ខេត្តកំពត ស្ថិតក្នុងវ័យ៧ឆ្នាំនាងត្រូវម្ដាយស្លាប់ចោលដោយសារជំងឺមហារីកសួត ចាប់ពីពេលនោះមកជីវិតនាងរសាត់មករស់នៅជាមួយម្ដាយមីងដែលរស់នៅក្នុងខេត្តកំពតនោះដែរទាំងគ្មានគោលដៅ ត្បិតឪពុកចាកចោលទាំងមិនស្រណោះ។

យុវតីវ័យ២២ឆ្នាំរូបនេះបានឲ្យដឹងអំពីជីវិតរបស់ខ្លួនថា៖«ខ្ញុំដឹងថា ជីវិតខ្ញុំអាចក្រោកឈរបានដល់ថ្ងៃនេះគឺដោយសារតែព្រះជាម្ចាស់បង្ហាញផ្លូវ និងដឹកដៃខ្ញុំតាំងតែពីកុមារភាព»។

សំនៀងបន្ថែមទៀតថា ខ្ញុំជួបការលំបាកជាច្រើនក្នុងជីវិត តាំងពីម្ដាយស្លាប់ចោល គឺជីវិតពឹងទៅលើការចិញ្ចឹមបីបាច់របស់ម្ដាយមីង ជួនកាលបានញ៉ាំជួនកាលអត់ ព្រោះសង្គមមនុស្សតែងតែជៀសមិនផុតអំពីការរើសអើង។ តែទោះបីជាយ៉ាងនេះក្ដីក៏ខ្ញុំមិនដែលភ្លេចការសិក្សា ព្រោះម្ដាយមីងបានឲ្យខ្ញុំចូលរៀនដូចកូនៗគាត់ដែរ។

រៀនបានត្រឹមថ្នាក់ទី៥ ដោយសារតែជីវភាពម្ដាយមីងក្រីក្រពេក នាងត្រូវបង្ខំចិត្តឈប់រៀនដើម្បីជួយធ្វើស្រែចម្ការ។

មិនយូរប៉ុន្មាន សំនៀង ត្រូវបានដូនជីកាតូលិកជនជាតិជប៉ុនម្នាក់ហៅឲ្យទៅរៀនវិញ ដោយប្រាប់ថាគាត់នឹងឧបត្ថម្ភលើការសិក្សារបស់នាង។ សំនៀងនិយាយថា៖ « ភ្លាមនោះខ្ញុំសប្បាយចិត្ត ព្រោះគិតថាអាចមានផ្លូវដើម្បីបន្តការសិក្សាវិញបាន តែក៏នឹកឆ្ងល់ថាហេតុអីពួកយេស៊ូចូលចិត្តជួយគេ ទាំងដែលមិនស្គាល់គ្នាសោះ ប្រហែលជាព្រះជួយហើយមើលទៅ»។

យុវតីរូបរាងស្ដើងទឹកមុខសុភាពរាបសាររូបនេះបន្តឲ្យដឹងទៀតថា បន្ទាប់ពីពេលនោះមក នាងក៏ទៅសិក្សានិងស្នាក់នៅក្នុងមណ្ឌលសិស្សនារីដែលគ្រប់គ្រងដោយដូនជីកាតូលិកជនជាតិថៃ ដែលមានទីតាំងនៅក្បែរព្រះវិហារកាតូលិកកំពង់រទេះ។ សំនៀងបន្តថា៖ «ក្នុងមណ្ឌលគឺធ្វើឲ្យខ្ញុំបានឃើញរូបឈើឆ្កាង រូបព្រះនាងម៉ារី ហើយមានព្រះគម្ពីរនិងសៀវភៅផ្សេងៗដែលទាក់ទងនឹងសាសនាកាតូលិក តែទោះជាយ៉ាងនេះក្ដីក៏ខ្ញុំមិនបាននឹកនាចង់ទទួលការអប់រំជំនឿដូចកូនសិស្សផ្សេងៗ ត្បិតក្នុងមណ្ឌលមានទាំងអ្នកដែលជាកូនគ្រីស្តបរិស័ទនិងពុទ្ធបរិស័ទ»។

សំនៀងបន្ថែមទៀតថា ការអប់រំប្រៀនប្រដៅរបស់បងស្រីនិងលោកបូជាចារ្យបានជ្រាបក្នុងចិត្តនាងជាខ្លាំង។ បន្តិចម្ដងៗ នាងបានសម្រេចចិត្តចង់ឈ្វេងយល់អំពីព្រះយេស៊ូតាមរយៈការចូលរៀនអប់រំជំនឿជាមួយបងស្រី និងសិស្សច្បងផ្សេងៗ។ សំនៀងថា៖«ក្នុងពេលវេលាដែលរៀននោះគឺហាក់ដូចជាប្លែកខ្លាំង ព្រោះតាំងពីតូចមកខ្ញុំមិនដែលបានទទួលការរៀនអប់រំជំនឿអីនោះទេ។ ហើយជួនកាលមិនដែលបានទៅវត្តស្ដាប់ធម៌ និយាយរួមគឺជឿទៅលើអ្វីមួយដោយមិនដឹងអំពីឫសគល់និងប្រយោជន៍សាសនាយ៉ាងដូចម្ដេចឡើយ តែផ្ទុយពីសាសនាកាតូលិកព្រោះគេដូចជាយកចិត្តទុកដាក់ក្នុងការនិយាយអំពីជំនឿ។ ហើយលោកបូជាចារ្យតែងតែនិយាយអំពីសេចក្ដីល្អ ហេតុនេះធ្វើឲ្យខ្ញុំស្រួលនៅក្នុងការស្ដាប់និងរិះគិតពិចារណា ជាពិសេសមានក្រុមយុវជន ក្មេងៗ និងមនុស្សចាស់តែងជួបជុំគ្នារាល់ថ្ងៃអាទិត្យមើលទៅដូចជាកក់ក្ដៅណាស់»។

រយៈពេលបីឆ្នាំក្នុងការរៀនអប់រំជំនឿនៅទីបំផុត សំនៀង បានទទួលអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទនៅព្រះវិហារគង្វាលដ៏សប្បុរស( កំពង់រទេះ ) ខេត្តកំពង់ធំក្នុងឆ្នាំ២០១២។

សំនៀងបន្តថា៖ «ខ្ញុំសប្បាយចិត្តរកអ្វីមកប្រៀបមិនបាន បើទោះបីជាគ្មានម្ដាយឪពុកមកលើកទឹកចិត្តគាំទ្រក្នុងការចូលខ្លួនជាសមាជិកព្រះសហគមន៍កាតូលិកក្ដី តែខ្ញុំដឹងថាព្រះជាម្ចាស់គឺជាអ្នកតម្រង់ផ្លូវឲ្យខ្ញុំមានឱកាសបានស្គាល់ព្រះអង្គ និងទទួលបានសេចក្ដីស្រលាញ់ពីមនុស្សនៅជុំវិញខ្លួន។ ជីវិតខ្ញុំដូចបានកើតម្ដងទៀត គឺក្នុងសភាពដែលលោកបូជាចារ្យចាក់ទឹកលើក្បាល គឺខ្ញុំបានសម្រេចចិត្តថា មិនថយក្រោយទេក្នុងការចូលរួមប្រកាសដំណឹងល្អ ហើយសន្យាថា និងខំប្រឹងរៀនសូត្រ កែប្រែជីវិតឲ្យរស់ដោយសេចក្ដីសង្ឃឹម និងភាពរឹងមាំ»។

ក្រោយបញ្ចប់ថ្នាក់ទី១២ សំនៀង បានបន្តការសិក្សា នៅទីក្រុងភ្នំពេញ ដោយមានអាហារូបករណ៍ពីមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិក។ ក្នុងកិច្ចការប្រកាសដំណឹងល្អនាងបានជួយបង្រៀន និងអប់រំជំនឿនៅព្រះសហគមន៍អរិយក្សត្របីឆ្នាំ និងចូលរួមកម្មវិធីសប្បុរសធម៌ចំពោះអ្នកក្រីក្រ និងក្មេងកំព្រាជាមួយសិស្សផ្សេងៗទៀតក្នុងមណ្ឌលនិស្សិត។ សព្វថ្ងៃ នាងជានិស្សិតឆ្នាំទី៤ផ្នែកចិត្តវិទ្យា ហើយកំពុងបម្រើកាងារក្នុងក្រុមហ៊ុនមួយកន្លែងនៅភ្នំពេញ។

សំនៀងបានប្រាប់ថា កញ្ញានៅតែមានទំនាក់ទំនងជាមួយម្ដាយមីងតាមរយៈការចុះសួរសុខទុក្ខ ទូរសព្ទ ជាញឹកញាប់។ សំនៀង៖ «បើទោះបីជាពេលខ្លះមានបញ្ហាជាមួយគាត់ តែខ្ញុំមិនបោះបង់គាត់ទេ ព្រោះខ្ញុំមានតែគាត់ដែលជាសាច់ញាតិ»។

សំនៀងបន្តថា មានតែការនៅស្ងៀមស្ងាត់ ហើយអធិដ្ឋានសន្ទនាជាមួយព្រះជាម្ចាស់ទេ ទើបធ្វើឲ្យនាងមានកម្លាំងដើម្បីបន្តដំណើរទៅមុខទៀត ធូរស្បើយពីទុក្ខកង្វល់។ សំនៀង៖ «ខុសពីមុន រាល់ពេលដែលមានទុក្ខរឺតូចចិត្តនឹងរឿងអ្វីមួយ គឺតែងតែពួនយំម្នាក់ឯងព្រោះគ្មានអ្នកនិយាយជាមួយ។ ហើយការអធិដ្ឋានកែចិត្តដែលតែងតែមាន ចិត្តលោភលន់ និងសេចក្ដីស្រណែន និងអ្នកដទៃឲ្យមើលឃើញអ្វីល្អៗវិញ។ ហេតុនេះបើទោះបីជាយ៉ាងណាសូមកុំភ្លេចព្រះជាម្ចាស់ ព្រោះអង្គជាពន្លឺបំភ្លឺផ្លូវយើងឲ្យគេចផុតពីសេចក្ដីអាក្រក់ទាំងឡាយណាដែលយើងមើលមិនឃើញ»។

រំលឹកអំពីឪពុកដែលបានបោះបង់នាងចោលក្នុងវ័យកុមារី សំនៀង បាននិយាយថា ឪពុករបស់នាងបានស្លាប់កាលពីនាងរៀននៅឆ្នាំទី៣ នៅមហាវិទ្យាល័យ។ តែទោះបីជាយ៉ាងណា នាងក៏បានអត់ទោសឲ្យឪពុករបស់នាងទៅតាមជំនឿដែលនាងបានទទួលពីព្រះជាម្ចាស់។

យុវនារីរូបនេះបន្ថែមថា តាំងពីដើមមកនាងមិនដែលគិតថា ខ្លួនមានឪពុកដូចគេឡើយ ព្រោះគាត់គ្មានការទំនាក់ទំនងទាល់តែសោះ បើទោះជាដឹងថាមានកូនស្រីម្នាក់ក៏ដោយ។ ហើយនាងក៏មិនដែលគិតថា ឪពុកនឹងវិលមករកនាងវិញដែរ។

យុវតីរូបនេះបានសំណូមពរដល់ឪពុកម្ដាយទាំងឡាយ ឲ្យលើកទឹកចិត្តកូនៗដើម្បីទទួលបានការសិក្សារៀនសូត្រ និងផ្ដល់ភាពកក់ក្ដៅដល់ពួកគាត់ ដើម្បីឲ្យពួកគាត់អាចក្រោកឈរដោយខ្លួនឯងនៅក្នុងអនាគត។

យុវនារីរូបនេះ បានផ្ដាំដល់យុវជនដូចគ្នាដែរថា៖«ចំពោះបងប្អូនកំព្រាទាំងអស់សូមមានកម្លាំងចិត្ត និងស្មារតីល្អក្នុងការរស់នៅ ព្យាយាមស្វែងរកផ្លូវដើម្បីក្រោកឈរ ហើយដើរទៅមុខទៀត ហើយកុំបោះបង់ចោលការសិក្សាព្រោះវាជាស្ពានចម្លងយើងចេញឆ្ងាយពីភាពល្ងង់ខ្លៅ។ បើទោះបីជាគ្មានអ្នកណាស្រលាញ់យើង តែព្រះជាម្ចាស់នឹងឃុំគ្រងជីវិតយើងម្នាក់ៗដូចក្មេងដែលមានម្ដាយឪពុកដែរ»៕



# ព្រះសហគមន៍កំពត និងសាសនាដទៃទៀត សួរសុខទុក្ខអ្នកជាប់ឃុំ៩២៣នាក់



*ព្រះសហគមន៍កាតូលិករួមនឹងសាសនាដទៃទៀត បានចូលរួមចុះសួរសុខអ្នកជាប់ឃុំនៅពន្ធនាគារខេត្តកំពត។ រូបភាព៖ ពន្ធនាគារកំពត*

*ដោយ៖ ខខខខខ*

ដើម្បីចែករំលែកអំណរសប្បាយក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត្រ ព្រះសហគមន៍កាតូលិកមណ្ឌលសកម្មភាពកំពត បានធ្វើការរៀបចំកម្មវិធីជួបសំណេះសំណាល និងសួរសុខទុក្ខ ជនជាប់ចោទ និងទណ្ឌិតចំនួន៩២៣នាក់ ក្នុងនោះមានស្ត្រីចំនួន២៤នាក់នៅក្នុងក្រុងកំពត។ កម្មវិធីនេះបានធ្វើឡើងកាលពីថ្ងៃព្រហស្បតិ៍ ទី១០ ខែមករា ឆ្នាំ២០១៩ ដោយមានតំណាងសាសនាធំៗចំនួន៣ចូលរួម ក្នុងនោះមានពុទ្ធសាសនា គ្រីស្តសាសនា និងអ៊ីស្លាមសាសនា និងមានវត្តមានអនុប្រធានមន្ទីរធម្មការខេត្តសរុបជាង៩០នាក់ផងដែរ។

ជាកិច្ចចាប់ផ្តើម លោក តាវូឡា ចនលូកា បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពកំពតបានមានមតិសំណេះសំណាលជាមួយបងប្អូនទណ្ឌិត និងជនជាប់ចោទទាំងអស់ថា ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត្រ ក្រុមគ្រីស្តបរិស័ទយើងមានអំណរជាខ្លាំង ព្រោះព្រះសង្គ្រោះរបស់យើងបានប្រសូតជាមនុស្ស ដើម្បីរំដោះបាបឲ្យយើងរាល់គ្នា។ លោកបន្តថា ព្រះសហគមន៍កាតូលិក ក្រសួងធម្មការួមនឹងតំណាងសាសនាធំ៣ទៀត បានមកជួបបងប្អូនសួរសុខទុក្ខក្នុងថ្ងៃនេះ ក្នុងគោលដៅចែករំលែកសេចក្តីស្រលាញ់។

លោក អូលីវីយេ ឆ្មិតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានបញ្ជាក់ថា ព្រះយេស៊ូសង្គ្រោះមិនមែនសំរាប់តែគ្រីស្តបរិស័ទនោះទេ គឺសម្រាប់មនុស្សទាំងអស់។

លោកអភិបាលបន្តថា ធម្មជាតិតែងត្រូវការពន្លឺដើម្បីមានផ្លែ មានផ្កា ហើយជីវិតរបស់មនុស្សក៏ដូច្នេះដែរ។ គ្រប់ផ្លែផ្កាទាំងអស់ទទួលបានមកពីទង្វើរដែលយើងបានប្រព្រឹត្ត។

ក្នុងនោះដែរ លោកអភិបាលបានធ្វើការលើកទឹកចិត្តដល់អ្នករស់នៅក្នុងពន្ធនាគារទាំងអស់កុំអស់សង្ឃឹម ប៉ុន្តែត្រូវចេះកែប្រែចិត្តគំនិត ត្រូវចេះពិចារណាទោសកំហុស និងត្រូវចេះកែខ្លួនឲ្យបានប្រសើរឡើងវិញសម្រាប់ពេលអនាគត។

លោកអភិបាល អូលីវីយេ បានបន្ថែមថា៖ «សូមឲ្យបងប្អូន (ទណ្ឌិត) ចំណាយពេលធ្វើសមាធិ ដើម្បីឲ្យចិត្តបានស្ងប់ និងរកឲ្យឃើញនូវតំលៃនៃជីវិត ក្រុមគ្រួសារ បងប្អូន ដើម្បីធ្វើយ៉ាងណាឲ្យពួកគាត់សប្បាយចិត្ត។ ព្រមជាមួយការកែខៃជីវិតរបស់ខ្លួនឯងឲ្យមានតំលៃសំរាប់ខ្លួនឯង និងសង្គមជាតិទាំងមូល»។

លោក ខេន ដិន អនុប្រធានមន្ទីរធម្មការខេត្តកំពត បានលើកឡើងថា មនុស្សយើងគ្រប់រូប មានសិទ្ធិទទួលយកការអប់រំតាមរយៈសាសនាផ្សេងៗ ដោយសេរី តែត្រូវគោរពទៅតាមច្បាប់ឬមាត្រាដែលប្រទេសយើងបានចែង។ សាសនាទាំងអស់គឺជាយាន ជួយចម្លងមនុស្សឲ្យទទួលបានសេចក្តីសុខក្នុងពេលបច្ចុប្បន្ន និងពេលអនាគត មិនត្រឹមតែប៉ុណ្ណោះពន្លឺនៃសាសនាជួយឲ្យយើងគ្រប់គ្នា ស្វែងរកឃើញនូវពន្លឺនៃជីវិត។

ស្ថិតក្នុងឱកាសនោះដែរ ឯកឧត្តម ង៉ែត សុខ ជាអាគារនុរក្សថ្នាក់លេខ៣ ក៏បានសម្តែងការពេញចិត្ត និងស្វាគមន៍ចំពោះវត្តមានរបស់តំណាងសាសនាផ្សេងៗ ដែលបានរៀបចំកម្មវិធីជួបសំណេះសំណាលជាមួយទណ្ឌិតចាប់តាំងពីឆ្នាំ២០០៤រហូតមក។ លោកថា វត្តមានរបស់សាសនាក្នុងពេលនេះសំខាន់ណាស់ ដើម្បីជួយអប់រំ លើកទឹកចិត្តដល់ទណ្ឌិតទាំងអស់ ឲ្យមានសេចក្តីសង្ឃឹម និងកែប្រែជីវិតរបស់ខ្លួនឲ្យប្រសើរឡើងវិញក្រោយពេលមានសេរីភាព។



*តំណាងសាសនាធំៗ ថតរូបអនុស្សាវរីយ៍នៅមុខពន្ធនាគារខេត្តកំពត។*



*រូបភាព៖ ពន្ធនាគារកំពត*

សូមបញ្ជាក់ផងដែរថា កម្មវិធីជួបសំណេះសំណាលជាមួយទណ្ឌិតក្នុងក្រុងកំពតនេះ បង្កើតឡើងដោយព្រះសហគមន៍កាតូលិកតាំងពីឆ្នាំ២០០៤ ដោយមានការចូលរួមពីក្រសួងធម្មកាក្រុង តំណាងខាងព្រះពុទ្ធសាសនា អ៊ីស្លាមសាសនា និងគ្រីស្តសាសនា។ ក្នុងនោះដែរ ក៏មានជាម្ហូបខ្លះៗដូចជា ការីធំប៉ុង សាប៊ូដុសខ្លួន ថ្នាំដុសធ្មេញ និងភួយជាដើម ជូនដល់អ្នកជាប់ឃុំទាំងអស់៕





*សមាជិកនៃសម្ពន្ធកាតូលិកដើម្បីមនុស្សធម៌ និងការអភិវឌ្ឍន៍ ជួបជុំគ្នាសំណាក់ធម៌អំពីបេសកកម្មនិងទិសដៅដើម្បីឆ្លើយតបនឹងសង្គម។ រូបភាព៖ស៊ីអេសស៊ី*

# CACD រិះគិតរួមគ្នាអំពីបេសកកម្ម និងទិសដៅដើម្បីឆ្លើយតបសង្គម

សម្ពន្ធកាតូលិកដើម្បីមនុស្សធម៌ និងការអភិវឌ្ឍន៍ (CACD) ជួបជុំគ្នាដើម្បីរិះគិតអំពីសកម្មភាព និងបេសកកម្មដោយផ្អែកលើទ្រឹស្តីរបស់ព្រះសហគន៍កាតូលិកនៅក្នុងសង្គម ដែលធ្វើឡើងនៅការិយាល័យកណ្តាលរបស់អង្គការការីតាសកម្ពុជា កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ដោយមានលោកអភិបាលអូលីវីយេ ឆ្មិតអីស្លែរ ជាអធិបតី និងមានអ្នកចូលរួមពីបណ្តាអង្គការកាតូលិក តំណាងការិយាល័យនីមួយៗ និងក្រុមបព្វជិត-ជីតាប្រមាណជាង៣០នាក់។

ក្នុងពេលចាប់ផ្តើមកម្មវិធីលោកអភិបាលបានលើកឡើងអំពីដំណើរការរបស់ក្រុមCACD នេះថា ក្រុមនេះបង្កើតឡើងដោយមានបីក្រុមចូលរួម គឺអង្គការកាតូលិក ក្រុមបព្វជិត-ជីតា ដែលមានសកម្មភាពក្នុងសង្គម និងក្រុមការិយាល័យមួយចំនួនក្នុងភូមិភាគភ្នំពេញ។ ក្រុមទាំងនេះធ្វើការងារមនុស្សធម៌ក្នុងការប្រកាសដំណឹងល្អគឺសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដោយឆ្លើយតបតម្រូវការរបស់មនុស្សក្នុងសង្គម។

ក្នុងនោះដែរ លោកអភិបាលបានបង្ហាញនូវសកម្មភាពមួយចំនួន ដែលព្រះសហគមន៍ បានចូលរួមក្នុងសង្គមក្នុងការផ្តល់នូវក្តីសង្ឃឹមដល់មនុស្សតូចតាច។ លោកអភិបាលអូលីវីយេ សង្កត់ធ្ងន់ថា ព្រះសហគមន៍គឺជាគ្រួសារធំមួយ ជាការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដើម្បីផ្តល់សេចក្តីស្រឡាញ់ ផ្តល់ក្តីសង្ឃឹម។

លោកបាននិយាយថា យើងត្រូវធ្វើឲ្យព្រះសហគមន៍ក្លាយជាឪពុកម្តាយសម្រាប់មនុស្សទាំងអស់។

លោក ម៉ាក ស៊ីលវ៉ា (MARC D'SILVA) ជាប្រធានអង្គការCRS CAMBODIA និងជាវាគ្មិនក្នុងអង្គពិធីប្រជុំនេះ មានប្រសាសន៍ថា យើងមិនមែនត្រឹមតែជាអង្គការប៉ុណ្ណោះទេ ហើយយើងក៏មិនធ្វើដូចជាក្រុមហ៊ុន ដែលមិនបម្រើដល់ជនក្រីក្រដែរ។ ទិសដៅរបស់យើងគឺឆ្លើយតបភ្លាមៗ ទៅតាមតម្រូវការរបស់ជនក្រីក្រ។

លោកបានលើកឡើងបន្តទៀតថា សង្គមបច្ចុប្បន្នមានការអភិវឌ្ឍន៍ខ្លាំងមែន តែអ្វីដែលយើងត្រូវអភិវឌ្ឍន៍នោះ គឺមនុស្សឲ្យគេមានចិត្តមេត្តាករុណា ចិត្តសប្បុរស គំនិតទូលំទូលាយ និងសេចក្តីស្រឡាញ់។



*សមាជិកនៃសម្ពន្ធកាតូលិកដើម្បីមនុស្សធម៌ និងការអភិវឌ្ឍន៍។ រូបភាព៖ស៊ីអេសស៊ី*

លោកបន្តថា នៅក្នុងប្រព័ន្ធការងារចាំបាច់ត្រូវតែអភិវឌ្ឍន៍មនុស្ស គឺធ្វើឲ្យល្អបំផុត និងជួយគេឲ្យមានបច្ចេកទេសកម្រិតខ្ពស់ និងមានមោទនភាពសម្រាប់ខ្លួន។ លោកម៉ាក បានបន្ថែមទៀតថា យើងក៏ត្រូវតែមានសាមគ្គីគ្នា ដើម្បីឲ្យមនុស្សទាំងអស់បង្ហាញសមត្ថភាពពេញលក្ខណៈ និងឲ្យរីកចម្រើនអស់ពីសមត្ថភាពរបស់ពួកគេ។ មិនត្រឹមតែប៉ុណ្ណោះ យើងក៏ត្រូវបង្កើតទំនាក់ទំនងជាមួយអង្គការនានា ដើម្បីចែករំលែកបទពិសោធឲ្យគ្នាទៅវិញទៅមកក្នុងការអភិវឌ្ឍន៍រួមគ្នា។

លោកបន្តថា យើងត្រូវចូលរួមយ៉ាងណាដើម្បីឲ្យវិស័យឯកជន ស្ថាប័នសាធារណៈ និងសង្គមស៊ីវិល ធ្វើដំណើររួមជាមួយគ្នា។ ហើយឲ្យយើងដែលជាស្ថាប័នកាតូលិកក្លាយជាគំរូ និងមានឥទ្ធិពលលើស្ថាប័ននានា។

នៅក្នុងកិច្ចប្រជុំនេះ អ្នកចូលរួមទាំងអស់បានចែកចេញជា៣ក្រុមធំៗ គឺ ដើម្បីចែករំលែកបទពិសោធ និងរិះគិតរួមគ្នាអំពីគ្រួសារ ការអប់រំ និងយុវជន ដោយផ្តោតសំខាន់អំពីបញ្ហាប្រឈមនានា និងអំពីសេចក្តីដែលស្ថាប័ននីមួយៗបានឆ្លើយតបដោះស្រាយបញ្ហាដែលជួបប្រទះ ព្រមទាំងរិះគិតធ្វើផែនការសកម្មភាព ដែលអាចអនុវត្តរួមគ្នាឲ្យមានប្រសិទ្ធភាពក្នុងការឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន និងដោះស្រាយបញ្ហានានាដែលគេប្រឈមផង៕

# រូបភាពសកម្មភាពស្ដីអំពី កិច្ចសន្ទនាអន្តរសាសនាដើម្បីសុខដុមរមនា និងសន្តិភាព





ព្រះសង្ឃ និងគណកម្មការអាចារ្យវត្ត អង្គមន្ត្រី និមន្ត និងអញ្ជើញមកព្រះវិហារកាតូលិក
ដើម្បីអបអរសាទរបុណ្យព្រះយេស៊ូប្រសូត



តំណាងសាសនាធំៗទាំងបី អញ្ជើញទៅសួរសុខទុក្ខអ្នកជំងឺ នៅមន្ទីរពេទ្យក្រុងព្រះសីហនុ
រៀបចំដោយព្រះសហគមន៍ក្រុងព្រះសីហនុ



កិច្ចសំណេះសំណាលរបស់លោកអភិបាលអូលីវីយេ
ជាមួយបងប្អូនក្នុងពន្ធនាគារខេត្តតាកែវ


Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវើរីតាស់អាស៊ីខេមរភាសា

សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវើរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយវិទ្យុ FM នៅភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្ដាប់កម្មវិធីផ្សាយរបស់វិទ្យុវើរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com និង www.catholiccambodia.org
- លោកអ្នក ក៏អាច Follow facebook ផ្លូវការរបស់យើងតាមរយៈ www.facebook.com/RVAKHMER/

**✣ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្ដាប់កម្មវិធីវិទ្យុវើរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬប្រព័ន្ធ IOS ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia រួច Download កម្មវិធីនោះដោយស្វែងរកប៊ូតុង (Khmer Live Audio)។

Radio Varitas Asia
Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com